# លេខ ៥

## ទស្សនាវដ្ដី

# មិត្តសាលាបាលី

ព.ស. ២៤៩៨

គ.ស. ១៩៥៥

ខែ ឧសភា



**សមាជិក នៃក្រុមអភិបាល សមាគមមិត្តសាលាបាលី**

**ឆ្នាំ ១៨៥៥**

ទីបាត់ការ

វត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ

អ្នកទទួលឲ្យជាវ

លោក ម៉ៅ·ម៉ុ ក្រសួងមហាផ្ទៃ (ក្រុងភ្នំពេញ)

...ម ១ ខែ ១០៛, ៦ ខែ ៥០៛, ១ ឆ្នាំ ១០០៛ ; ក្រៅប្រទេស ១ ខែ ១៣៛, ៦ ខែ ៦០៛, ១ ឆ្នាំ ១២០៛

បណ្ណាធិការ ហួត·ហៀម

ក 3ll ខ

2 34

# មាតិកាភឿង


១– វិចារណកថា . . . . . . . . . . . . . . មហា សម-ម៉ន ទំព័រ ១

២– ឆ្ពោះទៅរកសន្តិភាព . . . . . . . . . លោក ផេន-ជ្រ៉ាវ ៥

៣- សាមគ្គីជាធម៌មានឥទ្ធិពល . . . . . . . . . . មហា សម-សុខ ១០

៤– ស្លាប់ពីដីរមែកកើតជាមនុស្ស . . . . . . . . . . . . . . . . . ១៤

៥– លំនិតដែលខ្ញុំបានទទួល . . . . . . . . . . . . . . . . . . . . ១៨

៦– ការសិក្សាប្រទេសជប៉ុន (ត) . . . . . . . . . មហា-ឆាន់ ២០

៧– ចៅស្នេងទន្សាយផ្សងដំណើរផ្ទុំញាតិគតលោក . . . (តមកពីឆ្នាំ ១៩៥៤) លោក ក៉យ-ប៊ុក ២៤

៨– រឿងផ្លូវក . . . . . . . . . . . . តែងដោយតាំង-យត់សាន្តហៅស៊ិន ២៨

៩– រឿងមហាក្សត្រមួយព្រះអង្គ . . . . . . . . . . . លោក សាក់-សាមឿន ៣១


## សុភាសិត

៩ – លោកមើលពីខាងក្រៅ ជាអសមភាព លោកមើលពីខាងក្នុងជាសមភាព ។

១០ – មនុស្សមើលពីក្រៅមានច្រើន មនុស្សមើលពីក្នុងមានតែមួយ ។

១១ – លោកកោតខ្លាចអ្នកប្រើអំណាចសក្តិសក្តិនកស្ត្រជាងបណ្ឌិតអ្នកប្រាជ្ញ ។

១២ – ឧប្បត្តិហេតុដែលមានក្នុងជីវិតភាពរបស់មនុស្ស មានសភាពទុច្ចរិតចំពោះលោក តែ-សុចរិតចំពោះធម៌ ។

១៣ – ត្រូវយើងផ្លាស់ផ្ចាប់ថា និន្ទាកាលខ្វាប់ចិត្ត, សីលធម៌, ចរិយាផ្លូវជា លោកតែងផ្លាស់ធាតុពល់នាទីដូចនោះ ។

១៤ – ផ្កាណាដែលទៀងទោតមានខ្លួច, កក់, ហាលថ្ងៃគឺជាផ្កាល្អបំផុត ដើម្បីនឹងទៅកាន់ប្រាជ្ញាដ៏វិសេស ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| នារ | ៦០ | ២២ | នារី | នុលាផល | " | ២៥ | ផលានុផល |
| វិន្ទា | " | ២៥ | វិន្ទា | អាជព | " | ៤០ | អាជីព |
| ៣ឆ្នា | " | ២៧ | ៣ឆ្នាំ | ក្លាទៀង | " | ៤២ | ក្លាទៀយ |
| បងទឹងអន | ៦១ | ៣៥ | បងទឹងអូន | រត | " | " | រូប |
| របប់ | ៦៧ | ២១ | របស់ | តាំទុក | " | ៤៦ | តាំងទុក |
| ភាគ | " | ៣៤ | ភាគី | គ្មានរ៉ោ | ៦៩ | ៣១ | គ្មានរោ៉ |
| ដែលកស្វាម៉ | ៦៨ | ១២ | ដែលស្វាមី | ស៊ូប | " | ៤៤ | ស៊ូប្បុរ |
| ទេកាសល | " | ២៣ | ទេសកាល | | | | |

R. 6 23-7-55



# វិចារណកថា

## រស់នៅរួមគ្នាដោយសន្តិ តើដូចម្តេច?

"ការរស់នៅរួមគ្នាដោយសន្តិ" ជាវិធីមួយដែលគេតែងតែបានឮញយណាស់ក្នុងសម័យបច្ចុប្បន្ន សម្រាប់នយោបាយក្នុងប្រទេស ។

សេចក្តីពិត, បើគេពិចារណាដោយសើ ៗ រាក់ ៗ នោះ, សំដីពាក្យនេះស្តាប់ទៅពីរោះគួរឲ្យសរសើរ ព្រោះជាវត្ថុបំណងដែលសាកលលោកគប្បីប្រាថ្នា ។ ចំពោះមូស្គូវិញ ពាក្យនេះគេឃោសនាយ៉ាងខ្លាំងជាងគេ ហើយគេបានបញ្ជាក់ថា "ការរស់នៅរួមគ្នាដោយសន្តិ" គឺជាគំនិតរបស់សូវៀត ។

អាចមានពាក្យសួរថា ពាក្យមួយឃ្លានេះ តើមានសេចក្តីសំគាល់ដូចម្តេច ?

តើសេចក្តីអធិប្បាយរបស់កុម្មុយនិស្តនិង លោកសេរីដូចគ្នាឬទេ ?

មុននឹងនិយាយពីអ្វីទាំងអស់, យើងសូមរំលឹកជាដំបូងថា ក្នុងការធ្វើកិច្ចទាក់ទងដើម្បីចរចាគ្នារវាងលោកសេរីនិងពួកកុម្មុយនិស្តដែលបានធ្វើរួចមកហើយនោះ, ពាក្យមួយម៉ាត់នេះ អាចឲ្យសេចក្តីខុសគ្នាយ៉ាងច្រើន ទាំងផ្នែកខាងទ្រឹស្តី ទាំងផ្នែកខាងបដិបត្តិ ។ គេឃើញជាអាទិ៍ ដូចជាការប្រជុំប្រឹក្សារវាងសម្ពន្ធមិត្តនៅឱកាសសង្គ្រាមក្នុងពេលដែលកន្លងទៅហើយ ពេលនោះគេបាននិយាយដល់ពាក្យថា "លទ្ធិប្រជាធិបតេយ្យ" និងពាក្យថា "ការជ្រើសតាំងដោយសេរី" យ៉ាងក្រឹតញាប់ជាទីបំផុត, ប៉ុន្តែសំដីទាំងអស់នេះ មានចំណុចសំគាល់មួយសម្រាប់ស្តាលីន, ហើយមានចំណុចសំខាន់មួយទៀតសំរាប់លោកប្រធានាធិបតីរូស្វែលនិងលោកឈើរឈិល ។ ដូច្នេះកាលបើមាននិយាយដល់ពាក្យថា "ការរស់នៅរួមគ្នាដោយសន្តិ" ទៀត យើងត្រូវពិចារណាឲ្យល្អិតជាមុនសិន ថាវត្ថុបំណងនៃបក្សកុម្មុយនិស្តតើដូចម្តេច?

សម្រាប់វិធីខ្លះៗដែលយើងនឹកថាមិនជាអន្តរាយអ្វី, ព្រោះជាវិធីពីរោះស្តាប់នេះ កាលណាយើងសំឡឹងទៅរកវត្ថុបំណងរបស់លោកកាលម៉ាក្សនិងលោកស្តាលីន យើងនឹងអាចដឹងបានភ្លាមថាតើដូចម្តេចទៅ ? គេអាចឃើញផ្លូវនយោបាយនិងវិធីដំណើររបស់កុម្មុយនិស្ត ចំពោះការយកពាក្យនេះមកប្រើ ; ហើយពាក្យដូច្នេះ, ទំនងនេះ, មាននៅច្រើនទៀតក្នុងវចនានុក្រមនយោបាយខ្លួន ។

ពាក្យថា ការរស់នៅរួមគ្នាដោយសន្តិនេះ បើយើងពិនិត្យឲ្យច្បាស់លាស់ ឲ្យជ្រាលជ្រៅទៅ នឹងឃើញថា ជាពាក្យសាមញ្ញ សម្រាប់ពួកយើងដែលពុំមែនជាកុម្មុយនិស្តនិងគេ ។ ប៉ុន្តែពាក្យនេះមានសេចក្តីសំខាន់ខ្លាំងណាស់ ហើយហាក់ដូចជា "វត្ថុស័ក្តិសិទ្ធ" សម្រាប់បុគ្គលដែលជាសាវកដ៏ធ្ងន់របស់លោកកាលម៉ាក្សនិងលេនិន ។ តាមការពិត

សេចក្ដីសំគាល់នូវពាក្យធម្មតាថា វត្ថុជំស័ក្តិសិទ្ធនេះ ជាផ្នែកមួយនៃប្រព័ន្ធជាទស្សនវិជ្ជារួមសម្រាប់ប្រើក្នុងសាកលលោកនៃពួកបរិវារ កុម្មុយនិស្តទាំងឡាយមិនថាកុម្មុយនិស្តនោះនៅក្រោមប៉ុលកានិន ឬម៉ៅសេទុង ឬមួយនៅក្នុងសម័យស្តាលីន , ម៉ាលេនកាហ្វនោះទេ ។ គេដឹងច្បាស់ណាស់ថា ទស្សនៈវិជ្ជាបែបនេះជាទស្សនៈវិជ្ជាដែលគ្របសង្កត់ពួកកុម្មុយនិស្តទូទៅ ទាំងផ្នែកបដិបត្តិ ទាំងផ្នែកវិចារណ៍ ។

ក្នុងវត្ថុបំណងរបស់កុម្មុយនិស្តនោះ , ពាក្យថា "ការរស់នៅរួមគ្នាដោយសន្តិ" គឺជាគ្រឿងជំនួយមួយយ៉ាងវិសេសដើម្បីធ្វើឲ្យលទ្ធិម៉ាកស៊ីស្តមានអាការទ្រុឌបុះឬប៉ោងឡើងបានតាមចិត្ត ។

រួចគេពោលដោយខ្លីថា លទ្ធិម៉ាកស៊ីស្តមានប្រើភាសាតែមួយ គឺភាសានៃការសង្គ្រាម , សេចក្ដីហាយនៈ ។

លោកកាលម៉ាក្ស៍បានទំនាយទុកថា នឹងត្រូវបដិវត្តន៍សង្គម ដោយត្រូវកំចាត់នាយទុន , ពួកចក្រពត្តិនិយមនឹងពួកណាមកអាក្រក់ឲ្យវិនាសអន្តរាយទៅ ។ រួចហើយលោកកាលម៉ាក្ស៍ បានបញ្ជាក់ថាមនុស្សទាំងឡាយត្រូវស្មើភាគគ្នាទាំងអស់ គឺមិនត្រូវឲ្យមានឲ្យក្រ , ឲ្យថោកឲ្យខ្ពស់ ព្រោះសភាពទាំងនេះមិនមែនកម្មផលអ្វីតុបតែងទេ គឺពិតជាមនុស្សគ្នាឯងតុបតែងឡើងឲ្យមានខ្ពស់ទាបប៉ុណ្ណោះ ។

ដូច្នេះសាសនាក្ដី លទ្ធិអ្វីក្ដីដែលមានប្រលោមមនុស្សឲ្យនិយមទៅខាងបែងជាន់ បែងថ្នាក់ត្រូវរំលើងចោលឲ្យអស់ ។ល។

មានវត្ថុបំណងមួយធំជាទីបំផុត គឺត្រូវតាំងបក្សប្រជាជនមួយ ដែលមាននាទីត្រូវធ្វើឲ្យសាកលលោកទាំងមូល ដេរដាសទៅដោយទង់ក្រហមត្រាកណ្ដៀវនឹងញញួរ ។

សព្វថ្ងៃនេះដោយពួកកុម្មុយនិស្តពុំអាចតាំងខ្លួនជាម្ចាស់មេឃ ម្ចាស់ដីបានទូទៅ ដោយហេតុមានគេទប់ទល់ដោយអាវុធយ៉ាងសំខាន់ៗផង ហើយដោយគេស្អប់លទ្ធិដែលបដិសេធនូវកម្ម នឹងផលនៃកម្មផង ទើបពួកនេះខំផ្សាយតាមលទ្ធិរបស់ខ្លួន តាមរយៈជនជាន់ទាប ដែលច្រើនជាអ្នកប្រាថ្នាសម្បត្តិដោយពុំបាច់ធ្វើការងារឲ្យនឿយហត់ជាមុនសិន ព្រោះពួកមនុស្សជននេះងាយប្រដៅឲ្យឈ្លក់នឹងលទ្ធិខ្លួន ហើយគេទៅនឹងបានជាពួកខ្លួនទៀត ។ មិនតែប៉ុណ្ណោះ ពួកកុម្មុយនិស្តបានខំកសាងអាវុធសំខាន់ៗ ដើម្បីប្រហារក្រុមណាមួយដែលទទឹងទាស់នឹងខ្លួន ។

មនុស្សក្នុងលោកទាំងមូលដែលគេជ្រាបច្បាស់នូវកលឧបាយនេះ គេយល់ថា នៅពេលបច្ចុប្បន្នដែលពួកអ្នកធំខាងសូវៀតនឹងចិនក្រហម នៅពុំទាន់ចេញតស៊ូនោះដោយនៅខ្លាចខាងពួកលោកសេរី , ម្ល៉ោះហើយពួកនេះយកពាក្យថា " ការរស់នៅរួមគ្នា

•រដោយសន្តិ" មកប្រើសិន ៗ សូមកុំឆ្ងល់ឲ្យសោះ ថាពួកនេះនឹងសម្រាលចិត្ត សម្រាលគំនិតពីសេចក្តីប្រាថ្នា ដើម្បីបដិវត្តលោកសន្និវាសនេះ ៗ

យើងត្រូវនឹកដល់ស្តាលីននៅរស់នៅឡើយ , ពេលនោះស្តាលីនបានពោលនូវពាក្យ " រស់នៅរួមគ្នាដោយសន្តិ" ដូច្នេះដែរ ប៉ុន្តែការចាក់ក្រុកសាកលលោកនេះឲ្យជ្រួលច្របល់គឺចេះតែធ្វើជានិច្ចជាកាល ៗ ឥឡូវនេះស្តាលីនអស់សង្ខារទៅក៏ដោយ តែទស្សនវិជ្ជារបស់ស្តាលីនបានក្លាយជាគម្ពីររបស់សាវក គេប្រតិបត្តិតាមមកទៀតមិនរលត់ទេ ៗ

គេអាចឃើញអ្នកគ្រប់គ្រងវិមានក្រេមឡាំងតពីស្តាលីនមក បានប្រើនយោបាយឲ្យសាកលលោកច្រួលច្របល់ ទីងធ្វើឲ្យមនុស្សបែកចិត្តគំនិតពីគ្នា ដើម្បីគេអាចរំលើងបានដោយងាយ ៗ

យើងត្រូវនឹកម្យ៉ាងទៀតថា យើងរាល់គ្នាកាលពីមុននោះគ្មាននរណាមួយនឹកដល់លក្ខថាន ឬ សេចក្តីខុសត្រូវនៃសៀវភៅម៉ែនកង់ហ៍ ( Mein Kamf ) របស់ហ៊ិត្លែរឡើយ ស្រាប់តែមហាសង្គ្រាមធ្លាយផ្ទុះឡើងទើបនាំគ្នាភ្ញាក់ខ្លួន តែជាការភ្ញាក់ឥតអំពើ ព្រោះថ្ងៃហួសទៅហើយ ៗ

ក្នុងបច្ចុប្បន្ននេះ ពួកដែលសង្ឃឹមថា "អគ្យាក្រិត" ច្រើនព្យាយាមបំភ្លេចវត្តបំណងនៃទស្សនៈ របស់លោកកាលម៉ាកស៍អស់ ព្រោះទូតញ៉ាំងវាល់ "ការរស់នៅរួមគ្នាដោយសន្តិ" ៗ

សូមជ្រាបថាលោកស្តាលីន កាលដែលធ្វើអធិប្បាយអំពី "ការរស់នៅរួមគ្នាដោយសន្តិ" នោះ, លោកបានកំរិតថា " ខណ្ឌសីមាដែលកំណត់ឲ្យរស់នៅរួមគ្នាត្រូវគិតដល់របបគ្រប់គ្រងដែលផ្សេងគ្នាបានបញ្ចប់ទុក " បន្ទាប់មកស្តាលីនបានបញ្ជាក់ថា " គេតែម្នាក់ប៉ុណ្ណោះដែលមានសិទ្ធិវាយសេចក្តីអំពីពាក្យ " ខណ្ឌសីមា " នេះ ៗ

ក្នុងសៀវភៅដែលស្តាលីនបានតែងឈ្មោះសៀវភៅ " បញ្ហានៃលទ្ធិលេនិន " ស្តាលីនអធិប្បាយថា " ការបដិវត្តន៍សាកលលោកមួយរយៈ ១ នោះ ត្រូវប្រើវិធីផ្សេង ១ គ្នា " ៗ តមកទៀតថា "ឥឡូវ-ណោះការបដិវត្តន៍សាកលលោក បានចាប់ផ្តើមឡើងហើយ " ៗ លោកស្តាលីនបានបញ្ជាក់បន្ថែមតទៅថា "ពលំដ៏ធំក្រៃលែងនៃការបដិវត្តន៍ គឺលទ្ធផលចំការនៃជនថ្នាក់កម្មករក្នុងប្រទេសមួយ ហើយនឹងក្បួនចំពបដិវត្តន៍ នៃជនថ្នាក់កម្មករក្នុងប្រទេសដទៃ ១ គ្រប់ប្រទេសផង" ៗ ក្រៅពីនេះលោកស្តាលីនបានកំណត់ក្នុងសៀវភៅនោះនូវវិធីតទប់ផ្សេង ១ មានវិធីការ-តទប់ , ដោយកំឡាំង , ដោយការឃោសនា មិនវិធី

ការគោរព ហើយនឹងរបបនយោបាយផ្សេង ៗ យ៉ាងល្អិតល្អន់ផង ។

នយោបាយកុម្មុយនិស្ដដូចបានពោលមកខាងលើនេះមិនដែលប្រែប្រួលទេ , ដូច្នេះការដែលយកពាក្យ “ នៅរួមគ្នាដោយសន្ដិ ” មកប្រើយ៉ាងម៉ឺងម៉ាត់នោះ ពុំមែនជាការលើកលែងដើរនយោបាយរបស់ខ្លួនសោះឡើយ គឺត្រឹមតែប្រែប្រួលយុទ្ធវិធីឲ្យសមនឹងកាលៈទេសៈប៉ុណ្ណោះ ក្នុងពេលនេះខាងកុម្មុយ-និស្ដនៅខ្លាច ហើយនៅមានប្រាថ្នាកុំឲ្យមានសង្គ្រាមដាច់ខាតកើតឡើង , គេត្រឹមតែប្រាថ្នាឲ្យមានការបដិបក្សគ្នា រវាងពួកអ្នកប្រឆាំងនឹងលទ្ធិកុម្មុយនិស្ដតែម្យ៉ាង ៗ គេសង្កេតឃើញច្បាស់ថា ក្នុងពេលដែលមានប្រជុំធ្វើសន្ធិសញ្ញា SEATO ស៊ីអាតូឡើង ខាងរុស្ស៊ីនិងចិនក្រហមមានចិត្តជ្រះថ្លាក្រៃលែងដើម្បីឲ្យសន្និសីទអាហ្វ្រិកនៅបានឌុង កើតមានយ៉ាងឆាប់ ៗ ត្រង់ណេះ ព្រោះគេយល់ថា យ៉ាងហោចណាស់ក៏ល្មមនឹងប្រមូលធ្វើការឃោសនាឲ្យប្រទេសដែលតាំងខ្លួនជាអព្យាក្រិតកើតសេចក្ដីភិតភ័យចំពោះសន្ធិសញ្ញាស៊ីអាតូ (Seato) ហើយនឹងកើតសេចក្ដីសង្ស័យរវាងគ្នាឯងបានដែរ ។

តាមដែលយើងពិចារណាដោយកក់ៗ , ឃើញថារដ្ឋាភិបាលសូវៀតរុស្ស៊ី កំពុងឃោសនាយ៉ាងហឹកហាក់ជាបំផុត ដើម្បីឲ្យមាន “ ការរស់នៅរួមគ្នាដោយសន្ដិ ” ក្នុងប្រទេសនានានៃពិភពលោកនេះ ” ហើយក្នុងផ្នែកការទាក់ទងខាងការទូតក៏ឃើញថាសុភាពរាបសារទន់ភ្លន់ល្អណាស់ប៉ុន្ដែរុស្ស៊ីដែលនៅតែមានជំរុំទី២ជាជំរុំសម្ងាត់អែបធ្វើការជានិច្ចជាកាល ។

ដោយសហភាពរុស្ស៊ីពុំមែនជាប្រទេសដែលមាំមួនខ្លាំងពូកែល្មមនឹងរំលោភ ដោយការលើកទ័ពសំរុកទៅវាយនរណាឆ្ងាយៗនោះ , រុស្ស៊ីមានសង្ឃឹមតែទៅលើកលឧបាយនៃជំរុំទី២ ជាការធំបំផុត គឺធ្វើដូចម្ដេចឲ្យមានការឧបត្ថម្ភ និងការបំបែកប្រជាពលរដ្ឋនៃប្រទេសខ្លួនទៅ ហើយនឹងបំបែកប្រទេសនិមួយ ៗ ឲ្យបែកពីប្រទេសមួយទៀត ។ ធ្វើឲ្យមានការបដិវត្តន៍ខ្លួនទៅក្នុងលោកដោយវិធីសម្ងាត់ មិនបាច់អាស្រ័យការទូតឡើយ ។

សព្វថ្ងៃនេះ , នយោបាយ “ ការរស់នៅរួមគ្នាដោយសន្ដិ ” ជានយោបាយដែលនាំមកប្រើបានផលច្រើន , ហើយវិធីបន្ដឲ្យមានចលាចលក្នុងប្រទេសដទៃ ៗ រហូតដល់បន្ដឲ្យបះបោរក្នុងពេលឧស្សាហកម្មនៃលោកសេរីនិងការញុះញង់ឲ្យប្រទេសប្រជាធិបតេយ្យទាំងឡាយ កើតសៅហ្មងចិត្តនឹងគ្នាក៏ជាការញាំងផលល្អដល់ខ្លួនមិនតិចដែរ ។

កាលបើយើងដឹងដល់មូលដ្ឋាននៃការការណ៍ដូចបានពោលមកនេះ យើងគួរកំចាត់សេចក្ដីភ្ញាក់ផ្អើលឲ្យអស់ទៅ ។ មានតែសេចក្ដីតាំងចិត្តមុតមាំ

ហើយច្បាស់លាស់របស់យើងប៉ុណ្ណោះទេ ដែលនឹងរក្សាសន្តិសុខសេចក្ដីនិរភ័យបាន ហើយមួយទៀត សេចក្ដីពិតណាឲ្យច្បាស់លាស់ជាបទពិសោធន៍ឲ្យយើងរួចពីការឃោសនានៃពួកឈ្មួញកំនិងលទ្ធិម៉ាក់ស៊ីស្ទ



# ឆ្ពោះទៅរកសន្តិភាព

មុននឹងអធិប្បាយនូវរឿងនេះខ្ញុំសុំពោលអំពីន័យនៃពាក្យ "សន្តិភាព" សិន ។

សន្តិភាពគឺដំណើរនៃសេចក្ដីស្ងប់ ដំណើរនៃចិត្តដែលប្រាសចាកការក្ដៅក្រហាយ ការអន្ទះសាការខ្វល់ខ្វាយការអស់សង្ឃឹម ។

គេអាចសង្កេតឃើញមានសន្តិភាពពីរបែបគឺ សាមិសស្សន្តិភាព និងសន្តិភាពសុខ ។

សន្តិភាពទីមួយជាសន្តិភាពក្លែងក្លាយដែលលោកិយនិយមពេញចិត្តដោយគាត់ប្រកាន់ថាជាសន្តិភាពមែន—ទែនរបស់ខ្លួន ។ តើសន្តិភាពក្រៅនេះកើតមកពីអ្នកណា ? គឺកើតមកពីមនុស្សក្រៅខ្លួនដែរ ដូចផ្លែស្វាយរមែងកើតមកពីដើមស្វាយដូច្នោះ ។

អ្វីជាមូលហេតុនៃសន្តិភាព ? អ្វីជាមូលហេតុនៃអសន្តិសុខ ? មូលហេតុនៃសភាពទាំងពីរនេះ មិនមានអ្វីជាងការចិញ្ចឹមជីវិតឡើយ

នៅនាពិភពលោកដ៏មានរូបធំជាងសត្វចតុប្បាទនាលើផែនដីយ៉ាងណា ការចិញ្ចឹមជីវិតជាកិច្ចចម្បងជាងកិច្ចផ្សេងៗរបស់មនុស្សយ៉ាងនោះ ។ ព្រោះតែកិច្ចនេះ បានជាមនុស្សលោកមានចិត្តគំនិតបែកពីគ្នាហើយបង្កឲ្យមានជាគ្រួសារជាសង្គម ជារដ្ឋបំ មានរបៀបអាជីវកម្ម របៀបគ្រប់គ្រងនឹងទំនៀមទម្លាប់ផ្សេងៗគ្នាតាមធាតុអាកាសនិងទីស្ថាន ។ ទោះបីយ៉ាងដូច្នេះក្ដីគំនិតមួយដែលមកក្រៃលែងគឺលោភៈរមែងនៅមានជានិច្ចក្នុងរូបមនុស្សគ្រប់សង្គម ។ អំពើធម៌នេះទើបកើតមានឋានៈប្រើនុជាន់ ដែលខាងប្រទេសឥណ្ឌានិយមហេតុថា "វណ្ណបុត្តណ៍" ។

ឯរឿងឋានៈនេះមានសភាពមិនផ្សេងគ្នាប៉ុន្មានពីរឿងព្រេងដែលបុរាណតែងដំណាលថា ពស់ថ្លាន់ខ្លាក់ពិសពោល ពស់ឥតពិសដទៃព្រមទាំងត្រីទាំងឡាយ

នាំគ្នាមកដណ្ដើមស្រូបយកកំរៃលពិសនោះ ៗ អ្នកមកដល់មុនស្រូបយកមិនគិតដល់អ្នកមកបន្ទាប់ អ្នកនោះមិនគិតដល់អ្នកទីបី ហើយដូច្នេះរហូតទៅ ទាល់តែត្រីក្រម៉មកដល់ក្រោយគេបំផុត ឥតបានអ្វី តូចចិត្តត្រឡប់ជាឃ្លំហើមមុខអស់ ៗ តើយើងយល់ថាត្រីក្រម៉មពេញចិត្តនឹងខ្លួនគ្មានពិស ឬ បើពិតមែន ត្រីកសត់នេះមិនឲ្យអ្នកក្រឡត់មិនប្រព្រឹត្តចោរកម្ម គាក់អាវបៀតត្រិចមិនធ្វើកូដកម្មទេ ៗ អស់លោកអ្នកឥ នដែលព្រមទ័ព្វទេថា អ្នកមានថានៈខ្ពស់ធ្វើកូដកម្ម ដោយក្ដៅក្រហាយនឹងរ៉ាសនារបស់ខ្លួន ? អើ ! បើពួកនេះក្ដៅក្រហាយនឹងអ្នកក្រឡត់ ដែលធ្វើឲ្យរបេះផលប្រយោជន៍ដ៏សម្បូរលើសរបស់ខ្លួននោះ មានពិតមែន ៗ ដោយខ្លាចក្រែងជួបនឹងការខ្វះខាត ឬ ដោយខ្វះចិត្តមេត្តាអ្នកមានថានៈបង្ក្រមដែលក្លាយទៅជាសង្គមជារដ្ឋហើយបង្កើតនូវច្បាប់កម្មសិទ្ធិ ៗ តមកច្បាប់កម្មសិទ្ធិមានសមត្ថភាពមិនគ្រប់គ្រាន់សម្រាប់រក្សាផលប្រយោជន៍របស់ខ្លួន គេក៏ប្រើមធ្យោបាយបបរសាមបូក ដើម្បីបង្កើត សេនាហាននឹងសញ្ញៀផ្សេង ៗ ទៀត ៗ

លុះដល់ដំណាក់នេះ ពួកអភិជនមានសេចក្ដីកក់ក្ដៅគួរសម ព្រោះវត្ថុធាតុខាងលើអាចឲ្យគេស្ពានជាគេទទួលនូវសេចក្ដីសុខបាន ៗ ប៉ុន្តែ កុកហើរឮដអាកាសជាទីប្រទេសដ៏ទូលំទូលាយ ទីងជាទីរកពាយនៃសត្វស្លាបប្រហែលមិនក្ដួចផងដោយពេលដោយខណៈខ្វះ ចំណែករូបផងវិញ មិនដែលក្ដួចកុកដល់មួង់សោះ ៗ ព្រោះតែផងមិនដែលក្ដួចកុក បានជាគេមិនដែលឃើញមានសេចក្ដីសុខ សាន្តគ្រប់ទីកន្លែងលើពិភពលោកបានយូរឆ្នាំឡើយ ពោះវត្ថុធាតុជាគ្រឿងការពារមានសព្វគ្រប់ក៏ដោយ ៗ

ក្នុងជំនាន់ដែលអភិជនធ្វើរបងគឺសេនាហានព័ទ្ធជុំវិញកម្មសិទ្ធិរបស់ស្រួបហើយ ពួកអ្នកក្រហាក់ដូចជាជាប់ជើង អស់ផ្លូវសង្ឃឹម ៗ ម្ល៉ោះហើយគេបៀមតៀរទុក ដោយសំឡឹងផ្លៀកខចិត្តក្រៀមក្រំទៅជាទំកាលើនោះហើយខំរក់ប្រគោងឡើងទៅទៀតគឺធ្វើការចិញ្ចឹមជីវិតតាមយថា កម្មរបស់ខ្លួនទីទៃៗតាមផ្លូវណាដែលគេយល់ថាជាវិធានការអាចប្រព្រឹត្តទៅបាន ៗ

ត្រង់សម័យនេះហើយ ដែលលោកិយភ័ន្តប្រឡំថាគេមានសន្តិភាព តែតាមការពិតគឺគ្រាន់តែជាសាមិសស្រសន្តិភាពប៉ុណ្ណោះ ៗ ឧបមាដូចជាផងឆេះភ្លើងដែលកប់នៅក្នុងក្អក់ ពិតជាមិនឃើញមានអណ្ដាតលេចចេញមកខាងក្រៅជាសញ្ញាមែន តែនាខាងក្នុងនៅតែក្ដៅគគល់ ហើយរង់ចាំឲ្យតែមានឱកាសនឹងបញ្ចេញអណ្ដាតមកក្រៅ ៗ

ចូរយើងសំឡឹងមើល គេខំប្រឹងប្រកបអាជីវកម្មគ្រប់បែបតាមការយល់ឃើញនឹងតាមសមត្ថភាពរៀងខ្លួនយ៉ាងតក់ក្រហល់ ឥតឈប់ឥតឈរគ្មានគិតដល់

ពេលវេលាឡើយ ខ្លះតាំងពីព្រលឹមទល់ព្រលប់ឈប់តែពេលអាហារនិងពេលដំណេក ខ្លះទៀតយកថ្ងៃធ្វើយប់យកយប់ធ្វើថ្ងៃ ជាហេតុនាំឲ្យខុសប្រក្រតីភាពនៃធម្មជាតិដទៃទៀត ធ្វើការទាំងក្នុងដី ទាំងក្នុងទឹក ឰដ៏អាកាសឥតមានរអែងដល់គ្រោះថ្នាក់ដែលនៅរង់ចាំ ។

កាលបើការខ្វះខាតកាន់តែញាំញីខន្ធសន្តាននៃមនុស្សលោកជានិច្ចកាលយូរ ៗ ទៅងើកកើតឡើងខាងក្នុងក្អក់ក៏លេចអណ្ដាតគួបផ្ដុំមកក្នុងទីខាងណោះឬខាងណោះខ្វះក្នុងឱកាសដែលពួក. អភិជនកំពុងតែស្រវឹងនឹងសាមិសសន្តិភាព ។ បានជាយូរៗគេឮជាពាក្យថា នៅផ្សារឯណោះអ្នកលក់ដូរថ្លឹងអំបិលបំបាត់ក្នុងជញ្ជីង នៅផ្សារឯណោះមានមនុស្សឆក់លុយនៅតំបន់ឯណោះ អ្នកស្រុកគួរដោយរំលោភលើដីគេត្រូវកើតក្ដីនឹងគ្នា នៅតំបន់ឯណោះមានចោរប្លន់ នៅសាលាយុត្តិធម៌មានចៅក្រមកាត់ក្តីកោង នៅប្រទេសឯណោះមានកើតសង្គ្រាមហើយ នៅប្រទេសឯណោះមានគេសម្លាប់លោកនេះឬឯកឧត្តមនោះហើយ ។

ទាំងនេះគឺជាលទ្ធផលនៃសន្តិភាពក្រៅ ៗ សូមអស់លោកក្រឡេកមើល ដោយតក់ក្រហល់នឹងការខ្វះខាតឬដោយភ័យ ក្រែងមានការខ្វះខាតមកដល់មនុស្សលោកមានសភាពគ្រុនញាក់ជានិច្ច ដូចដង្កូវក្នុងបន្ទិចឬដូចសត្វនរកពួកមួយ កើតកដៃប៉ុនចបកាប់ចាប់ខ្ទាចតែគ្នាឯងស៊ី ពួកតូចស៊ីតូច ពួកធំស៊ីធំ ។

មែនពិត ជនណាប្រកបមុខរបរណា បេះតែគិតតែលៃប្រព្រឹត្តអយុត្តិធម៌ ក្នុងមុខរបរនោះដូចពាក្យចំនៀមថា "ត្រីឆៀតឆ្លៀតពង" ។ តែអ្នកប្រព្រឹត្តនូវអំពើខាងលើនេះអាចដឹងក្នុងដួងចិត្តថា ខ្លួនធ្វើនូវអ្វីឬទេ ? ត្រង់នេះមានជនភាគច្រើនមិនយល់ថាខ្លួនធ្វើខុសទេ ចំណែកជនដទៃផ្សេងយល់ដែរតែការខ្វះខាតដែលជះជាន់ខ្លាំងពេក បង្ខំគ្នាឲ្យត្រូវទ្រាំមិនធ្វើមិនកើត ។

សូមលោកប្រៀបដូច្នេះជាកាទំ. សុនខ កាលបានជួបនឹងលាមកហើយបរិភោគ មិនគិតដល់ការខ្ពើមរអើម ព្រោះតែអាហារមិនគ្រប់គ្រាន់.... ។ គឺការមិនគ្រប់គ្រាន់នេះដែលព្រះពុទ្ធសំដែងថា ជាប្រភពនៃអសន្តិសុខ ដែលពួកអភិជនយកសព្វាវុធនឹងទាហានមកបង្ក្រាបការពារ ហើយនាំគ្នានិយមទុកជាជា "សន្តិភាព" របស់ខ្លួន ។

សេចក្តីដែលពោលរៀបខាងលើ ហាក់ដូចជាថាក្នុងពិភពលោក គេមិនអាចរកនូវ "សន្តិភាពសុខ" បាន ។ មិនមែនទេ ! កាលបើមានពិណាទៅហើយពិណាសគង់តែនឹងមានដោយពិតប្រាកដ បើគេត្រូវការ ។ ព្រះពុទ្ធទ្រង់សម្តែងថា តែមានកន្លែងឲ្យទុក្ខ កន្លែងឲ្យសុខប្រាកដជាមាន ។

ដំណើរដូចម្តេច ក៏នៅនាលោកិយ គេមិនសូវជួបប្រទះនឹង "សន្តិភាពសុខ" ? កុំពោលពី

ប្រទេសតូចៗចុះ ព្រោះថាជាប្រទេសមានសភាពទន់ខ្សោយតាំងព្រេង ។ ដំណើរដូចម្ដេចក៏ប្រទេសមហាអំណាចទាំងឡាយមិនកែមធ្យោបាយដើម្បីបង្កើតសន្តិភាពដ៏ស្ថិតថេរ? ដូចខ្ញុំបានពោលមកខាងលើស្រាប់ថា ពួកនេះអាចបង្កើតសន្តិភាពចំពោះបុគ្គលឬសន្តិភាពភ្លើងក្លក់ប៉ុណ្ណោះឯង ។

សន្តិភាពសុខ មិនអាចកើតមាននៅស្រុកណាដែលមានពាក្យថា: "អំណាច" ទេ ។ អស់លោកជ្រាបទេ "អំណាច" ក្លាយមកពី "អាច" អើ! បើអាចនៅត្រង់ណា "ស្ងួត" ត្រូវតែដកខ្លួនថយចេញព្រោះសភាពទាំងពីរនេះជាប្រតិបក្សនឹងគ្នា បុរាណតែងពោលទុកថា: "គ្រូអាច សិស្សខូច" ។

សព្វថ្ងៃប្រទេសមហាអំណាចដើរបំពើមគេឯង ពាសពេញក្នុងពិភពលោក ដូចជាពស់វែក ដែលនៅប្រស្រ័យនឹងពស់ឥតពិសផ្សេងៗ មានពស់ទាន់តាមមជាដើម តើលុះមានការសម្រាលមកគេឃើញកូនពស់អ្វីខ្លះ? បើយ៉ាងនេះតើគេត្រូវបន្ទោសអ្នកណា!

ដូច្នេះ ដើម្បីត្រោះទៅរកសន្តិភាពសុខ ការចិញ្ចឹមជីវិតប្រកបដោយសម្មាអាជីវ: "ជាការចាំបាច់" ។ យ៉ាងដូចម្ដេចហៅថា "សម្មាអាជីវ:?" គឺការចិញ្ចឹមជីវិតមិនគិតដល់ការខ្វះខាត មិនក្រែងជួបនឹងការខ្វះខាតគឺ ការចិញ្ចឹមជីវិតស្លូតត្រង់ប្រកបដោយចិត្តមេត្តា ។ ព្រោះករណីយកិច្ចជាចម្បងនៃមនុស្សលោកគ្មានអ្វីក្រៅពីការចិញ្ចឹមជីវិតឡើយ ។ ហេតុដែលបញ្ជាក់បន្ថែមទៅលើសេចក្ដីខាងលើ គឺត្រង់ដែលគេរួមគ្នាជាបឋមហើយ គេរមែងសួរគ្នាមុនដម្បូងបង្អស់ថា: "សុខសប្បាយជាទេ! រកស៊ី! ចម្រើនឬទេ!" ។ សំដីដែលខ្លាតចេញពីមាត់ឯង ១ មុនសំដីអ្វីដទៃដូច្នេះនេះ សរឲ្យឃើញថាជាបឋមកិច្ចនៃមនុស្សជាតិ ដូចជាកូនក្មេងដែលមិនចេះនៅស្ងៀមបង្ហាញឲ្យដឹងថា ជាតិមនុស្សកើតមកត្រូវតែធ្វើការយ៉ាងដូច្នោះដែរ ។

ប៉ុន្តែ បើយើងមិនបានជាគិត យើងមុខជាស្មានខុសថាពួកកម្មករដែលខំលីសែង តាំងពីព្រឹកទល់ល្ងាចហើយមិនទាំងពាក់អាវផង មានតែខោខ្លីជាឱបមួយបង្កើះ បែកញើសគយោរកណ្ដាលថ្ងៃ ធ្វើការដើម្បីប្រយោជន៍អ្វីដទៃ មិនមែនទេ! គឺប្រយោជន៍តែស្មាដែលកំពុងលីសែងគគ្រាក់ចុះ គគ្រាក់ឡើងនេះឯង ។ បើយើងមិនបានគិត យើងមុខជាស្មានខុសទៀតថាពួកទាហានដែលខំប្រតិបត្តិការឥតគិតដល់ជីវិតអាត្មាដល់មាតាបិតា ដល់កូនប្រពន្ធជាទីស្នេហា កណ្ដាលសមរភូមិ ស៊ូទ្រសឹងតែក្ស័យនឹងសស្ត្រាវុធ ដូចជាជីវភាពនៃសត្វនរកកណ្ដាលអាកាសឥតបង្អែក កណ្ដាលសាគរឥតកោះឥតត្រើយជាទីពឹង ដើម្បីប្រយោជន៍អ្វីដទៃ មិនមែនទេ! គឺប្រយោជន៍តែដៃដែលកំពុងកាន់កាំភ្លើងនេះឯង ។

បើយើងមិនបានជាគិត យើងមុខជាស្មានខុសថា ប្រមុខរដ្ឋផ្សេង ៗ ដែលចំប្រឹងជំនុំការ រំពឹងពិចារណា ដោយកលល្បិចរៀងខ្លួន ខុសពេលខុសវេលា ឆ្លងកាត់ទាំងយប់ទាំងអធ្រាត្រ ពីប្រទេសមួយទៅប្រទេសមួយ ធ្វើការដើម្បីប្រយោជន៍ដទៃ មិនមែនទេ ! គឺប្រយោជន៍តែមាត់ដែលចំនិយាយដដែក ហើយដែលធ្វើការតាមផ្លូវនេះ អ្វីទាំងអស់ចូលមិនចេះពេញម្ដងៈ សារៈនេះឯង ៗ បើយើងមិនបានជាគិត មុខជាស្មានខុសថាគេធ្វើសង្គ្រាម ដែលជាប្រភពនៃសេចក្ដីវិនាសដល់ជីវិតមនុស្សរាប់លាននាក់ ហើយ មនុស្សទាំងនេះគឺមាតាបិតាចំបីបាច់ថ្នាក់ថ្នមមិនឲ្យគាត់ ទាំងពីប្រសូតមក សូម្បីតែស្រមោចមួយពាំលើពុំបាន បើមានជម្ងឺអ្វីបន្តិច គេស្ទុះទៅរកថ្នាំរកពេទ្យ ដែល រក្សាបាលសាបនាឡើង អស់ប្រាក់ជាច្រើនទុកសម្រាប់ លុះដល់ពេញរូបពេញកងត្រូវគេកេណ្ឌបង្ខំឲ្យទៅបាញ់គ្នាជាល្បែង ដើម្បីប្រយោជន៍អ្វីដទៃមិនមែនទេ, ដើម្បីតែការខ្វះខាតបំពោះជីវភាពនេះឯងប៉ុណ្ណោះ ៗ

ដូច្នេះ ដើម្បីឲ្យមានសន្តិភាព ទើបព្រះពុទ្ធជាលោកនាថ ទ្រង់បញ្ជ្រៀញពេលអាហារនៃពុទ្ធបរិស័ទរបស់ព្រះអង្គឲ្យខ្វីមកគឺជាព្រះអង្គបញ្ញត្តិ ឲ្យទទួលអាហារភោជនតែរយៈពេលមួយភាគបួន ក្នុងម្ភៃបួនម៉ោង ៗ ដើម្បីអះអាងចំពោះបញ្ហានេះ ត្រូវយើងសង្កេតមើលថយទៅក្រោយតាំងពីថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចាស័កជាកាលបរិច្ឆេទ នៃពុទ្ធបរិនិព្វាន ហើយ

ពិនិត្យហូរហែតាមលំដាប់មកទល់នឹងបច្ចុប្បន្នកាលនេះ យើងមុខជានឹងមិនបានជួបប្រទះនឹងសង្គ្រាមណាមួយ ៖ ទោះបីតូច ឬធំដែលផ្ដើមកើតមានពីខាងព្រះពុទ្ធសាសនាដោយពិតប្រាកដ ៗ សេចក្ដីនេះហើយដែលអាចកំណត់ឲ្យយល់បានថា “ សម្មា-គារវៈ ” ជាប្រភពនៃសន្តិភាពសុទ្ធ ៗ

សូមអស់លោកជ្រាបថា មនុស្សយើងសុទ្ធសឹងជាអ្នកដំណើរ ៗ ប៉ុន្តែយើងច្រើនតែភ្លេច? គឺលោកៈដែលតែងយាយីនាកណ្ដាលមាគ៌ា ៗ គឺលោកនេះឯងហើយជាប្រភពនៃអសន្តិសុខ ជាប្រភពនៃសង្គ្រាម ៗ គ្រប់គម្ពីរណាដែលមនុស្សបេះកម្រិតព្រំដែននៃលោកៈ ឲ្យស្ថិតនៅក្នុងក្របខណ្ឌធម៌សុទ្ធនៃខ្លួន គ្រប់គម្ពីរនោះ មនុស្សច្រើនរមែងជួបប្រទះនឹង “ សន្តិភាព ” ដោយពិត ៗ

ជេង - ជ្រីវ

# សាមគ្គីជាធម៌មានឥទ្ធិពល

ក្នុងសព្វលហុសូត្រ គម្ពីរអង្គុត្តរនិកាយ អដ្ឋនិបាត

ព្រះសាស្តាត្រាស់ថា៖



"ម្នាលភិក្ខុទាំងឡាយ ការញុះញង់ដែលបុគ្គលបានធ្វើហើយ ជាអំពើប្រព្រឹត្តទៅ ដើម្បីអបាយគឺនាំឲ្យអន្តរាយសេចក្តីសុខផ្ទាល់ខ្លួន និងសេចក្តីសុខដល់អ្នកដទៃ ៗ ឲ្យបុគ្គលអ្នកប្រព្រឹត្តនិយាយចាក់ដោតបំបែកបំបាក់ដទៃ ការបែកបាក់នោះនឹងត្រឡប់មករកខ្លួនវិញ ហើយគ្មានសាមគ្គីជាជំនួយដល់ប្រទេសផង ៗ ឯកន្លែងណាសម្បូណ៌មនុស្សអ្នកពោលពាក្យញុះញង់ កន្លែងនោះមុខជាមានសេចក្តីទុក្ខច្រើន ឲ្យខូចប្រយោជន៍ទាំងនាំឲ្យថោកទាបដល់ប្រទេសជាតិជាដើម, ហើយមនុស្សអ្នកពោលពាក្យញុះញង់នោះ ស្លាប់ទៅទៀតតែកើតក្នុងនរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន រងទុក្ខលំបាកយ៉ាងក្រៃលែង លុះផលកម្មនោះស្រាលបន្ធូរ បានមកកើតជាមនុស្ស តែងទ្រុស្តមិត្រ ឥតនរណាមួយទុកចិត្តស្និតស្នាលឡើយ ៗ

យើងសូមអធិប្បាយពង្រីកព្រះពុទ្ធភាសិតនេះ ជូនជាសណ្តាប់ដូចតទៅ៖

សំដីញុះញង់ជាសំដីធ្វើឲ្យបែកសាមគ្គីធម៌ នឹងជាទោសយ៉ាងធំបំផុត ៗ ការមិនមានសាមគ្គីធម៌នេះហើយ ដែលធ្វើប្រទេសជាតិឲ្យធ្លាក់ទៅនៅក្នុងកណ្តាប់ដៃរបស់អ្នកដទៃដោយពិត ៗ ការអន្តរាយសាមគ្គីធម៌ កើតឡើងដោយហេតុច្រើនប្រការ គឺឧបក្កិលេស, អគតិ នឹងទិដ្ឋិជាដើម ៗ ហេតុទីមួយគឺ

## ឧបក្កិលេស ១៦ យ៉ាង

១ – ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ដោយបំពាន

ច្បាប់សម្រាប់រដ្ឋ(ឆក់-លួច-ប្លន់)

២-ប្រទុស្តរាយអ្នកដទៃ ចង់ឲ្យតែគេវិនាសអន្តរាយ

៣-កំហឹងឃោរឃៅទ្រឹស្តិ៍ស្ទុះស្ទើរជាតិមារយាទអប្រិយ

៤-ចងកំហឹងទុក ដើម្បីនឹងសងសឹកក្នុងពេលក្រោយ

៥-រំលើគុណគេ, បំបាត់គុណបំណាច់របស់គេ

៦-វាយឫកយ៉ាងខ្លាំង, លើកកំពស់ខ្លួនឯងដូចជនទន់ជាមនុស្សគ្មានសីលធម៌ មិនចេះខ្មាសគេគ្មានរបៀបសណ្តាប់ធ្នាប់ ខ្វះអាចារ:

៧-ប្រវ័ណនឈ្នានីស ; ផ្តល់ទុក្ខលំបាកដល់គេ ចង់តែឲ្យគេវិនាសទាំងទ្រព្យទាំងអាយុជីវិត

៨-កំណាញ់ស្វិតស្វាញ(កំណាញ់ជាក់ទឹកមិនលេច)

៩-មានពុតត្បុតអាក្រក់, មារយាទបោកបាប, ឫកពារពុំសមជាមនុស្សជាតិ

១០-អួតអាងហើយបែបអែបអបផ្គាប់ផ្គុនប្រាថ្នាលាភសក្ការ:យសសក្តិ

១១-គោងកាចពេក, ព្រហើនហួស, ប្រទើស លើសតែម្នាក់ឯងមិនចុះសម្រុងនឹងគេ

១២-ប្រកាន់ថាត្រាន់ជាងគេ (គ្មានអ្នកណាស្មើខ្លួន)

១៣-ប្រកាន់ខ្លួន, ក្រអឺតក្រទម, តែម្នាក់ឯង

១៤-មើលងាយគេ(ថាអន់ជាងខ្លួនទាំងសព្វ)

១៥-ស្រវឹងល្បួង ជ្រប់ល្អក់ក្នុងលាភ-យស-សុខ-សរសើរ

១៦- ធ្វេសប្រហែសស្មារតីជានិច្ចកាល ។ ហេតុទីពីរគឺ:

## អគតិ៤យ៉ាង

១-លំអៀងដោយការយល់មុខមាត់ស្រឡាញ់មិនចង់បែក

២-លំអៀងដោយទោសចិត្ត ព្រោះស្អប់ចង់តែធៀសវាង មិនប្រាថ្នាឲ្យជួបប្រទះ

៣-លំអៀងទាំងបំពាន ព្រោះមោហ៍បាំងពាំងពេញមុខ មិនស្គាល់ខុសត្រូវអាក្រក់គុណទោស

៤-លំអៀងដោយខ្លាចចិត្តគំនិតបុណ្យសក្តិគេ ទាំងប្រើអាការអែបនែបដោយសារគេ ។ ហេតុទីបីគឺ

## ទិដ្ឋិ ២ យ៉ាង

១- មិនជឿថាមានស្ថានសួគ៌-នរក និងបុណ្យបាប គិតតែស្អិតស្អាងរាងកាយឲ្យហួសហេតុដោយគិតថាខ្លួននឹងថ្កើងទាន់សម័យនិយម

២-គិតតែប្រយោជន៍ខ្លួន, ពោះខ្លួន, ហោះប៉ៅខ្លួន, ក្រុមគ្រួសារខ្លួន, សង្គមខ្លួន មិនគិតដល់ប្រទេសជាតិ មាតុភូមិ និងវង្សត្រកូលអ្នកដទៃផងសោះៗ

មនុស្សដែលប្រកាន់តាមធម៌ទាំងនេះ គឺសុទ្ធ

តែជាអ្នកបំផ្លាញប្រទេសជាតិ បន្តុះបង្អាប់ប្រទេសជាតិ មិនដឹងគុណប្រទេសជាតិ ធ្វើឲ្យប្រទេសទៅជាទាសភាព ធ្វើឲ្យពួកជនដែលរួមសញ្ជាតិ រួមឈាមជ្រប់មុខ អាប់កិត្តិយសជានិច្ច ធ្វើឲ្យសាសនាថោកទាប ដុនដាបជាងសាសនាដទៃ ។

ការបែកសាមគ្គីរវាងគ្នាឯងនេះ គឺជាទោសយ៉ាងធំសម្បើម គឺយ៉ាងដូចពួកបព្វជិតជំនាន់ពុទ្ធសម័យ នៅកាស្រ័យក្នុងក្រុងកោសម្ពិក : វត្តឃោសិត : បែកសាមគ្គីជាពីរពួកគឺ ពួកធម្មកថិកនិងវិនយធរ ដោយហេតុសព្វបើទឹកសម្រាប់ជម្រះលាមកប៉ុណ្ណោះ ក៏បណ្តាលជាទាស់ទែងខ្វែងគំនិត ដែលទុកចិត្តគ្នាមើលគ្នាមិនត្រង់ ប្រកាន់គណបក្សរៀងៗខ្លួន ។ ពួកឥស្សរជនទាំងឡាយមានព្រះចៅក្រុងកោសម្ពិក: ជាប្រធាន បានមកនិយាយអង្វរករយ៉ាងណាក៏មិនព្រមស្តាប់ នៅតែចចេសរឹងរូសប្រកួតប្រណាំងយកមុខយកអំនួតតែសព្វខ្លួន ទាល់តែគេលែងជ្រះថ្លា លែងប្រគេនចង្ហាន់ឆាន់ លែងថ្វាយបង្គំកប់អានពេញនិគមជនបទទាំងអស់ ។ ទាំងព្រះសាស្តាបរមគ្រូទៀតសោត ក៏ស្តេចយាងមកឃាត់ដែរ តែភិក្ខុទាំងនោះមិនព្រមស្តាប់សោះ ទើបយាងទៅគង់ឯព្រៃបាលិលេយ្យកទៅ ។ ភិក្ខុទាំងនោះកាលបើឥតបាយមានកាយស្គាំងស្គម មានកំលាំងពលំទន់ខ្សោយហើយនឹងមើលទៅអនាគតទៀត ថាមុខជាឥតប្រយោជន៍ឥតបានការអ្វីសោះ ក៏ព្រមខ្លួនមានសាមគ្គីធម៌រាប់រកគ្នាវិញ ។

គ្រប់តែប្រទេសបើនាម៉ឺនសព្វមុខមន្ត្រី និងប្រជា-រាស្ត្រ បើបែកសាមគ្គីធម៌ហើយ មុខជាមានសត្រូវមើលងាយ ច្បាំងដណ្តើមយកភោគទ្រព្យនិងប្រទេសជាពុំខាន ដូចជាព្រះបាទអជាតសត្រូវ រឹបអូសយកប្រទេស សម្បត្តិស្តេចលិច្ឆវីវជ្ជីនោះ ។ ស្តេចលិច្ឆវីមានឥទ្ធិពលខ្លាំងមហិមា ព្រោះបានរក្សាអបរិហានិយធម៌មិនឲ្យឃ្លៀងឃ្លាត ។ ពេលក្រោយព្រះបាទអជាតសត្រូវជាស្តេចដែនមគធ : មានព្រះបំណងទៅច្បាំងយកដែនវជ្ជីនោះ តែដោយពួកលិច្ឆវីក្សត្រប្រតិបត្តិតាមអបរិហានិយធម៌ជាប់លាប់ក្រៃពេក ក៏មិនអាចនឹងរឹបជាន់ យករាជសម្បត្តិក្នុងដែននោះបានឡើយ ។ លុះកន្លងមកខាងក្រោយ ពួកស្តេចលិច្ឆវីក្សត្រដែនវជ្ជីបែកសាមគ្គីធម៌លែងទុកចិត្តគ្នា , មិនយូរប៉ុន្មាន ព្រះបាទអជាតសត្រូវក៏លើកទ័ពទៅលោមព័ទ្ធម្តងទៀត ច្បាំងដណ្តើមយកដែននោះមកដាក់ជាចំណុះឋិតនៅក្នុងសហពន្ធន៍ របស់ព្រះអង្គបានដោយងាយ មិនព្រួយនឹងបាក់ទ័ពរត់ថយដូចកាលលើកមុននោះឡើយ ។

ហេតុការណ៍ដែលឲ្យវិនាសយ៉ាងនេះ គឺមកពីបែកសាមគ្គីធម៌ ។ សាមគ្គីធម៌ បើបែកហើយកុំសង្ឃឹមរកសេចក្តីសុខ - ចំរើននោះមិនឃើញទេ ដូច

គួយ៉ាងដែលបានពណ៌នាមកខាងលើនេះស្រាប់ ៗ

សាមគ្គីនេះ ចាត់តាមកំណើតមាន ៣ គឺ

១ – សាមគ្គីដោយកាយ : គ្រប់ប្រទេសទាំងអស់ក្នុងលោកសន្និវាស ដែលមានអារ្យធម៌, វប្បធម៌និងសីលធម៌ អាចឈានដើរពីភាពជាប្រទេសសោតម្រក់ ទៅកាន់ភាពដ៏ឧត្តមពោលគឺឯករាជ្យ ត្រូវចំណុចចិត្តរបស់ពលរដ្ឋបាន មិនមែនដោយអាស្រ័យកំលាំងជនម្នាក់ៗនោះទេ គឺត្រូវអាស្រ័យសាមគ្គីរវាងពលរដ្ឋទូទៅ ៗ តាមការពិត គឺការស្រុះស្រួលព្រមព្រៀងគ្នាចំពោះសមាគម ចំពោះប្រទេសជាតិ មិនឲ្យមានការបែកបាក់ជាគណបក្ស ពួកនយោបាយផ្សេងៗពីគ្នានោះ រមែងជាបច្ច័យនាំមកនូវសេចក្តីសុខ. ចំរើន អាចប្រតិស្ឋានសមាគមប្រទេសឲ្យមានថាមពលដ៏ប្រពៃ មានឯករាជ្យជាត្រើមុខអស់កាលជាយូរលង់ ឥតមានឧបសគ្គ ឬគណបក្សនយោបាយជនបរទេសណា ហ៊ានមកពាំងកំផែងយាយីអារ្យធម៌ឯករាជ្យនោះបានឡើយ មានតែគេខ្លាចញញើតដោយគេយល់ថា សមាគមនោះ ប្រទេសនេះស្រុះស្រួលមូលមិត្តគ្នាណាស់ ៗ ការមានកំលាំងពលំរក្សាសមាគមប្រទេសឲ្យគង់វង្សជាឯករាជ្យ ដ៏ស្ថាពរនេះគឺមកពីការរួបរួមគ្នាជាចាំបាច់ ប្រៀបដូចជាអម្បោះដែលជាវត្ថុផុយបំផុត ក្នុងបណ្តាអវិញ្ញាណវត្ថុទាំងឡាយ តែបើគេយកច្រើនសរសៃមកវេញត្របាញ់បញ្ចូលគ្នាជាដុំមួយ គេអាចយកអម្បោះនោះទៅចងអតិមហាពលសត្វទាំងឡាយ មានដំរីរាជសីហ៍ជាដើមជាប់បានដោយងាយ, ឯដំរីរាជសីហ៍ជាដើមនោះ ជាសត្វមានកំលាំងខ្លាំងមហិមា ធំមាឌទៀតសោតក៏ពិអស្ចារ្យ តែពេលជាប់ចំណងអម្បោះដែលវេញបញ្ចូលគ្នាកាលណាហើយ ក៏មិនអាចកើតក្រឡាក់បម្រះឲ្យរួចពាក់ចំណងនោះបានឡើយ ៗ មនុស្សទាំងឡាយ គ្រប់ប្រទេសបើមានសាមគ្គីរួបរួមគ្នាជាដុំមួយ ក៏អាចចងក្រៀកខ្ទុកនូវឯករាជ្យមិនឲ្យឃ្លាតបាន ដូចជាដំរីរាជសីហ៍ដែលជាប់ចំណងអម្បោះដូច្នោះដែរ ៗ

២ – សាមគ្គីដោយវាចា : មនុស្សក្នុងភពលោកមានសំដីភាសាផ្សេងៗពីគ្នាជាអនេក បើរាប់ចំនួនបាន ២៧៩៦ ភាសា ៗ ពលរដ្ឋជាតិណាដែលគេស្រឡាញ់ជាតិមាតុភូមិរបស់គេពិតប្រាកដ គេតែងគោរពស្រឡាញ់សំដីភាសា ស្រឡាញ់អក្សរសាស្ត្រដែលជាដើមកំណើតភាសាគេណាស់ គេយល់ថាភាសារបស់គេពិរោះពិសា ត្រឹមត្រូវ ហាស្ដិយាយកាលណាគួរឲ្យចង់ស្ដាប់ បើទុកជាកិច្ចការខាងអាណាចក្រ ក៏គេនិយមប្រើសំដីភាសារបស់គេដែរ, ក្នុងប្រទេសរបស់គេ ៗ លើកយកភាសាជាតិគេជាផ្លូវការ ទោះទាក់ទងដោយផ្លូវនយោបាយយ៉ាងណា ឬទាក់ទងនឹងប្រទេសដទៃ ក៏គេមិនព្រមលះបង់សំដីភាសាជាតិគេ, គេស្រឡាញ់ភាសាជាតិគេទាំងអ្នក

រាជការ ទាំងប្រជារាស្ត្រ ព្រមព្រៀងគ្នានិយាយតែភាសាគេ សរសេរតែអក្សរសាស្ត្រគេ ប៉ុន្តែភាសាអក្សរសាស្ត្រដទៃ ក៏រង្គាក់បាលគេបាត់វិធានការបង្គាប់ឲ្យពលរដ្ឋទៅរៀនតាមស្ម័គ្រចិត្តដែរ គឺរៀនបានដោយសេរី ។ ដោយហោចទៅសូម្បីតែសត្វតិរច្ឆានទាំងឡាយ មានសារិកាជាដើម ដែលមកនៅក្នុងសំណាក់មនុស្ស ហើយត្រូវគេបង្វឹកបង្ហាត់ឲ្យរៀននិយាយស្ដីជាភាសាមនុស្ស ចេះចាំស្ទាត់ចំនាញអស់កាលយូរ ក៏គង់តែមិនភ្លេចភាសារបស់វាដែរ វាចៀតនិយាយភាសាវាជាមួយនឹង សត្វសារិកាផងគ្នា ដែលហើរមកជិតវា ឃើញថាវាជាសត្វមានសេចក្ដីស្នេហាចំពោះភាសាវាណាស់ ។

ចុះយើងជាមនុស្ស មានគុណធម៌ខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន បើយើងមិននិយម និយាយសំដីយើង អក្សរសាស្ត្រយើង យើងមិនអន់ជាងសត្វតិរច្ឆានដែលជាសត្វខ្វះខាតធម្មសញ្ញាទៅហើយ ។

ជនរួមជាតិ រួមសាសនាទាំងឡាយ !

គួរយើងក្រឡេកមើលអារ្យធម៌បុព្វបុរសយើងជំនាន់វង្សវរ្ម័ន សម័យអង្គរវត្ត ដែលសាងបាសាណប្រាសាទធំៗ នៅក្នុងខេត្តសៀមរាបសព្វថ្ងៃនេះ ដូចជាទេពនិម្មិត ប្រសិទ្ធិថ្វាយតាងនាមវិស្សកម្មទេវបុត្រជាវិស្វករចំណានមួយរូប ចំពោះព្រះមហារាជយើងនោះយើងនឹងឃើញច្បាស់នូវអារ្យធម៌ខាងសំដីភាសានិងអក្សរសាស្ត្រដែលឆ្លាក់ក្បាច់រស់រវើកនៅនឹងជញ្ជាំងមហាប្រាសាទទាំងនោះ នេះមកពីការនិយមប្រើសំដីភាសា អក្សរសាស្ត្រជាតិ បានជាមានអនុជនបានដឹងឮច្បាស់ថា ជាកេរ្ដិ៍ដំណែលរបស់បុព្វបុរសរបស់យើងមែន ។

បើមានពេលទំនេរ គួរអស់លោកអញ្ជើញទៅទស្សនាផ្ទាល់ខ្លួនចុះ មុខជាមានការស្ងើចសរសើរ ថាបុព្វបុរសយើងចេះសង្គ្រងភាសា អក្សរសាស្ត្រមិនឲ្យវិនាសដោយបានឆ្លាក់ជាក់ផ្ទាំងសិលា ជាពិតប្រាកដ ។

យើងជាអនុជន ដែលបានទទួលកេរ្តិ៍មរដកដ៏ប្រសើរគឺភាសានិងអក្សរសាស្ត្រពីបុព្វបុរសមកហើយត្រូវយើងនិយមប្រើភាសា អក្សរសាស្ត្រយើង ត្រូវស្រឡាញ់ភាសាអក្សរសាស្ត្រឲ្យដូចជាស្រឡាញ់ខ្លួនយើង ការពាររក្សាភាសា អក្សរសាស្ត្រយើងឲ្យមែនទែន ត្រូវនាំគ្នារាប់រកកុំស្អប់ កុំខ្ពើមឲ្យសោះ-ព្រោះបើភាសាអក្សរសាស្ត្រយើងវិនាសហើយជាតិយើងក៏មុខតែវិនាសទៅតាមដែរ, ភាសាទុកដូចជាមាតា អក្សរសាស្ត្រដូចបិតា ជាតិទុកដូចជាកូនបើម្ដាយឪពុកវិនាសហើយ កូនមុខតែវិនាសដោយពិត ។

ម្យ៉ាងទៀត គួរយើងនឹកដល់សុភាសិតបុព្វបុរសយើងថា „សំដីជាឯក „ ឲ្យចាំជាក់ក្នុងចិត្តរៀងៗខ្លួន កុំគប្បីធ្វេសប្រហែសបំភ្លេចចោលឲ្យសោះ ព្រោះសំ-

ដីនេះឯងជាព្រលឹង ជាថ្លើមបេះដូង ជាជីវិតរបស់ជាតិ គួរស្ងួនគ្រងភាសាជាតិឲ្យដូចជាស្ងួនគ្រងខ្លួនគ្រប់ ៗ គ្នា ។

តាមស្មានដោយភាគច្រើន អ្នកនានាប្រទេសទាំងឡាយ គេថាថា នៅសមាគតរដ្ឋនេះជាទីក្រុងចំរបស់បារាំង ព្រោះនិយមកប់គានតែភាសាបារាំង គ្រង់ភាសាខ្លួនមិនសូវនិយម ទើបតែពេលដែលព្រះមហាវីរបុរសស្តេចធ្វើព្រះរាជដំណើរតំទួពិភពលោក យកបញ្ហានេះទៅលាតត្រដាងបង្ហាញថា នៅសមាគតរដ្ឋ មានប្រទេសខ្មែរមួយដែរ ដែលមានភាសានឹងអក្សរសាស្ត្រប្រើគ្រប់ - ។

(មានត)



## ស្លាប់ពីដំរីមកកើតជាមនុស្ស

មានឧបាសិកាចាស់ម្នាក់ នៅខែត្រសៀមរាប សព្វថ្ងៃនេះគាត់មានអាយុជាង ៦០ ឆ្នាំហើយ នៅតង់កញ្ចឹងកគាត់ គេឃើញមានស្បែកមួយដុំក្រាស សណ្ឋានជាស្បែកដំរីសុទ្ធ ហើយមានរោមដុះលើស្បែកក្រាសនោះសុទ្ធសាតជារោមដំរី ។

គេបានសួរគាត់ពីហេតុដែលមានមកនេះ ; ជនចាស់ក៏រៀបរាប់រឿងរ៉ាវគាត់ដូចតទៅ :

ខ្ញុំពីជាតិមុនមានកំណើតជាដំរី កាលនោះគ្រួសាររបស់ខ្ញុំបានទុកដាក់ឲ្យខ្ញុំមានប្តី រយៈដែលខ្ញុំនៅរួមជាមួយនឹងប្តីនោះ មិនជាយូរប៉ុន្មានក៏បានកូនប្រុសមួយមានទាំងភ្លុកដុះចេញមកផង ប្តីរបស់ខ្ញុំស្រឡាញ់កូននោះណាស់បានថ្នាក់ថ្នមយ៉ាងវិសេស មិនឲ្យមានសៅហ្មងដល់កូននោះឡើយ , មានថ្ងៃជាខាងក្រោយមក កូនប្រុសសម្លាញ់របស់ខ្ញុំក៏កាន់តែចំរើនវ័យធំឡើង ភ្លុកទាំងគូរក៏កាន់តែដុះវែងធំជាលំដាប់ដែរ ; គាប់ជួនជាអកុសល កូនប្រុសសំឡាញ់របស់ខ្ញុំនោះ ត្រូវព្រានបាញ់បានយកទៅ ដោយប្តីរបស់ខ្ញុំរវល់ដើរកស៊ី , លុះត្រឡប់វិញបានដឹងហេតុថា កូនសំឡាញ់ត្រូវព្រានបាញ់យកទៅហើយ វាក៏ក្តៅក្រហាយយំសោកបោកខ្លួនពេញទាំងព្រៃ ហើយវាក៏បានតាំងចិត្តចំពោះមុខខ្ញុំថាសូមលាខ្ញុំចេញទៅតាមកូន តែការដែលទៅតាមនេះនឹងក៏កំណត់ពេលយ៉ាងយូរត្រឹម ៣ ឆ្នាំ បើមិនឃើញត្រឡប់វិញទេទើបអនុញ្ញាតឲ្យខ្ញុំយកប្តីទៀត. ចាប់តាំងពីពេលនោះមកវាក៏ចេញដើររហូតទៅ ; ខ្ញុំបានរង់ចាំ-

ណើរគិតរយៈកាល ២ ឆ្នាំនិង ១១ ខែគត់ពុំឃើញប្ដីខ្ញុំនោះវិលមកវិញសោះ កំសន្និដ្ឋានក្នុងចិត្តថាប្រហែលជាបាត់បង់ជីវិតទៅហើយ , ក្នុងពេលជាបន្ទាប់នោះខ្ញុំក៏ព្រមទទួលយកប្ដីមួយទៀត, ក្នុងថ្ងៃដែលត្រូវសារទាំងពីរខាងបានរៀបចំផ្សំផ្គុំផល់គូសង្សារប្ដីរបស់ខ្ញុំនេះ រួចហើយ ក៏ស្រាប់តែលេចមុខប្ដីខ្ញុំមកដល់, និមិត្តតែមកដល់ភ្លាម ពុំបាននិយាយស្ដីនឹងខ្ញុំសូម្បីមួយម៉ាត់សោះ គ្រាន់តែដឹងហេតុនោះភ្លាម ក៏ទាត់ធាក់ខ្ញុំបីបួនជេង ប៉ុណ្ណោះ ខ្ញុំក៏ទទួលទុក្ខវេទនាអស់សង្ខារក្នុងពេលនោះមួយរំពេច ហើយក៏បានមកយកកំណើតជាមនុស្សលុះសព្វថ្ងៃនេះ ។

ជួនចាស់គាត់បញ្ជាក់តទៅទៀតថាជាតិសត្វដែលសប្បាយជាងគេក្នុងលោកគ្មានសត្វណាសប្បាយជាងជ្រូកទេ ជ្រូកជាសត្វសប្បាយគ្មានទុក្ខព្រួយ ហើយជាសត្វរក្សាបវេណីរបស់ត្រកូលយ៉ាងខ្ជាប់ខ្ជួន និងមានសាមគ្គីយ៉ាងក្រៃលែង ជាសត្វចេះស្ដាប់បង្គាប់មេនាយជាទីបំផុត សត្វជ្រូកមានរបៀបណាស់ចំពោះចៅហ្វាយ មិនចេះលាក់លួចចុកនាយអាយឡើយ ការនៅរួមសុខទុក្ខជាមួយនឹងជ្រូកណាមួយបាន លុះត្រាតែមានការព្រមព្រៀងត្រកូលទាំងសងខាង និងសាមីខ្លួនទៀត ហើយបានរៀបការឲ្យពរជ័យដោយត្រឹមត្រូវផង ទើបនៅរួមគ្នាបាន ដែលគេសន្មតថាជាប្ដីប្រពន្ធ ប្ដីប្រពន្ធនោះត្រូវមានចិត្តស្មោះត្រង់នឹងគ្នាអស់មួយជីវិត ជ្រូកណាមួយដែលបានល្មើសក្បត់នឹងគូទ , ប្រពន្ធប្ដីគេនោះនឹងត្រូវហ្វូងជ្រូកផងគ្នាប្រហារជីវិតចោល គាត់បានបញ្ជាក់ថែមទៀតថា ជ្រូកទាំងឡាយសុទ្ធតែនៅដោយហ្វូងដោយក្រុម ដែលមាននាយជាអ្នកត្រួតត្រា បើយើងបានឃើញជ្រូកណាមួយបែកចេញពីហ្វូងនោះ គេត្រូវដឹងថាជាសត្វគោងកាច ប្រព្រឹត្តអំពើទុច្ចរិតក្នុងហ្វូង ហើយលួចរត់ចេញ ដោយខ្លាចគេដឹងរឿងខ្លួន ជ្រូកទុច្ចរិតនេះចូលទៅនៅជាមួយនឹងក្រុមណាដទៃទៀតមិនបានដោយដាច់ខាត គ្មានហ្វូងណាមួយគេទទួលឲ្យនៅទេ បើនៅតែប្រឹងសុំចូលនៅជាមួយនឹង ៗនឹងសម្លាប់ចោល ដោយគេយល់ថាជាសត្វទុច្ចរិតម្នោះ ហើយក៏ត្រូវរស់នៅជាមួយនឹងគូខូច កាចរបស់ខ្លួន ដោយមិនហ៊ានទៅជិតហ្វូងគេឯងឡើយ ។ ជ្រូកជាសត្វពេញគ្រប់គ្រាន់ដោយសាមគ្គី គឺថាមិនដែលប្រព្រឹត្តផ្ទុយការបង្គាប់បញ្ជារបស់នាយ . ក្នុងពេលដែលមានអាសន្នក៏ដូចជាពេលធម្មតា មិនចេះឈ្លោះទាស់ទែងគ្នាឬវាយចាក់គ្នាឡើយ នៅរក្សាសេចក្ដីសុខក្នុងហ្វូងរបស់ខ្លួនជាទីបំផុត ។ ក្នុងហ្វូងនីមួយៗ គេបានចាត់ទុកជ្រូកមានភ្លុកដូចជាព្រះអង្គម្ចាស់ ព្រោះជ្រូកមានភ្លុកតែងតែមានជ្រូកស្ត្រីពីរការពារជានិច្ច បើជ្រូកណាមានភ្លុកវែងហួសហេតុដើររកស៊ីមិនបានជ្រូកផងគ្នាត្រូវរកស៊ីចិញ្ចឹមជ្រូកមួយនោះ ហើយការពារដូចជាស្ដេចរបស់ខ្លួន

បើតាមការរៀបរាប់ដោយសង្ខេបនេះ គេឃើញថាដំរីជាសត្វមានរបៀបរបប ដោយមនុស្សសុទ្ធសាធ ឬក៏ថ្លៃថ្នូរជាងមនុស្សជំពូកខ្លះទៀតផង, យើងគួរពិចារណាមើល មនុស្សនឹងដំរីមានសភាពផ្ទុយគ្នាយ៉ាងណា? ក្នុងសម័យនេះ; យើងត្រូវរក្សាសេចក្ដីស្ងប់រៀបរយ ដូចជាដំរីរក្សាសេចក្ដីស្ងប់ក្នុងហ្វូង ។

X

X X

ឮថាមានជនអ្នកបៀតបៀន ដល់សាសនាទៀតហើយ

ឮថាអ្នកសូមផ្នួសជាច្រើន បានសុំអនុញ្ញាតពីសាលាស្រុកហើយត្រូវបរដំរីយកទៅផងទើបបាន

ឮថា មានកន្លែងខ្លះត្រូវបញ្ញត្តបំពោះអ្នកសុំផ្នួស មិនចេះវិន័យ មិនឲ្យបួស ហេតុនោះបានជាមានចាត់ឲ្យសួរវិន័យមុនសុំផ្នួស ការនេះល្អពេកណាស់តែទីណាដែលមានបញ្ញត្ត ទីនោះ នៅតែមានមនុស្សដប់គត់ចូលបួសដដែល ដោយអ្នកត្រូវការ អាងសែនដំរីហ្វូង; ដូចជានៅសាលាស្រុកពួក គេឃើញដំរីហ្វូងរបស់ជនអ្នកមិនចេះវិន័យ ចូលហៅបាវក្នាក់ងារសាលាស្រុកជាច្រើន ។

ចុះបើយើងចេះតែអនុលោមតាមហ្វូងដំរីដូចនោះ តើធ្វើម្ដេចឲ្យភិក្ខុ ក្នុងសាសនាចេះដឹងធម៌វិន័យបានច្រើន ធ្វើដូចនេះ ទុកដូចជាយើងបបួលគ្នាជាន់សាសនាពន្លិច យើងបានកើបស្រូវរបស់ព្រស្ដខ្លះហើយ ម្ដេចក៏បង់កើបស្រូវក្នុងសាសនាទៀត ។

សូមទីពឹងសេចក្ដីនេះលើក អ្នកឧញ៉ាចៅហ្វាយស្រុកគ្រប់កន្លែង មានលោកចៅហ្វាយស្រុកពួកជាដេមមេត្តាជួយពិនិត្យរឿងនេះផង ដើម្បីបំបាត់ កុំឲ្យមនុស្សចូលបួសបង្ខំក្នុងព្រះពុទ្ធសាសនាបាន ។

X

X X

ឆ្នោតជាតិមួយសន្លឹកថ្លៃតែ ១០៛ទេ ដល់ត្រូវបានកំរៃ ៥០០.០០០៛ សូមមិត្រប្រញាប់ទិញបន្តិច ប្រយ័ត្នដល់ថ្ងៃអង្គារឬពុធអ្នកលក់ឆ្នោតគេនឹងឆ្លៀតសុំយើង ១៛ ថែមទៀត បើយើងមិនឲ្យគេសុំថ្លៃក្រោយគេចំណាំមុខបាន ហើយយើងសួររកឆ្នោតគេ ៗ ថាគ្មានទេ មានតែឆ្នោតដែលគេយករួចអស់ទៅហើយ តែគេធ្វើទុក; បើឆ្នោតជាតិលក់ដាច់ច្រើន ក៏គួរបង្កើនចំនួនឆ្នោតថែមទៀត ដើម្បីកុំឲ្យមានការសុំ ១៛ ពីអ្នកទិញ ។

ឮថា អ្នកសិក្សាច្បាប់ព្រះពុទ្ធសាសនា ដែលមានសញ្ញាប័ត្រមហាឧត្តមវិជ្ជាបរិយត្តិ ភ្លេចឋានៈរបស់ខ្លួន ប្រព្រឹត្តអំពើមិនគប្បីជាច្រើនជំពូកមានអបាយមុខទាំងបួនជាដើម មិត្រភ្លើបែបនោះប្រហែលជាចង់បំផ្លាញកេរ្តិ៍ឈ្មោះរបស់មិត្រយើងហើយ ដោយមិនបានប្រតិបត្តិតាមច្បាប់ដែលបានសិក្សាមក សូមមិត្ររក្សាសេចក្ដីថ្លៃថ្នូររបស់ក្រុមយើងផង កុំឲ្យគេពោលទោសច្រើនពេក គួរភ្ញាក់ខ្លួនខ្លះទៅ ព្រោះ

យើងជាអ្នកនៅក្នុងសង្គមសាសនា ដើម្បីជាការថ្លៃថ្នូរ ដល់បណ្ឌិតអ្នកកាន់កាប់ នូវសាសនារបស់យើង

សួស្ដីមិត្រអាចលះបង់អបាយមុខបាន

X

X X

១ – បើតាមសេចក្ដីអង្កេតអង្គការសុខភាពសាកល ថាពស់មានពិសធ្វើឲ្យស្លាប់មនុស្ស, ក្នុង១ឆ្នាំចំនួន៣ ហ្មឺនឬ៤ហ្មឺននាក់គឺ:

ទ្វីបអាស៊ី មានចំនួនមនុស្សស្លាប់ ដោយសារពស់ចឹក ២៥.០០០នាក់ ឬ ៣០.០០០នាក់ ទ្វីបអាមេរិកខាងត្បូង៣០០០ ឬ៤០០០ នាក់ប្រទេសបារាំង,២១នាក់ប្រទេស អ៊ីតាលី ១៨នាក់ ប្រទេសអង់គ្លេស៨ នាក់, ប្រទេសអេស្ប៉ាញ៥នាក់ ។

អង្គការសុខភាពសាកលថ្លែងថា នៅក្នុងពិភពលោកមានពស់២.៥០០ បែបមានអំបូរផ្សេងៗ ១៣; ពស់២០០បែបបែងចែកជាអំបូរ៤យ៉ាង ជាពស់មានពិស ។



លិខិតដែលខ្ញុំបានទទួល

ឆុង-ឆៅ អតីតសិស្សសាលាបាលីជាន់ខ្ពស់

ខ្ញុំបាទសូមក្រាបប្រណិបត៌ន៍ចំពោះលោកដែលជាអតីតសិស្សច្បងខ្ញុំបាទ សូមជ្រាប

ខ្ញុំបាទមានសេចក្ដីជឿនថ្កល់ចំពោះលោកជាប្រធានសមាគមមិត្តសាលាបាលីយើង . ដោយខ្ញុំបាទបានចេញទៅធ្វើគ្រូបង្រៀនពីរឆ្នាំហើយ មិនដែលឃើញដំណឹងអំពីសមាគមនោះ ទើបតែក្នុងឆ្នាំ ១៩៥៥ នេះ ឃើញសារាចរពិសេសមួយលេខទៅតាមក្រសួងសិក្សាធិការ គ្រើនរំលឹកដល់អតីតសិស្សសាលាបាលីជាន់ខ្ពស់ ដោយឲ្យជួយចុះជាទស្សនាវដ្ដីសមាគម ។ ខ្ញុំបាទដែលធ្លាប់ ឮ សូរយោបល់នៃទារកសមាគមមិត្តសាលាបាលីនេះ យំក្តុងៗ តាំងពីកាលខ្ញុំទៅជាសិស្សនៅឡើយ ហើយបំភ្លេចចោលយូរហើយនោះ កក្រាក់ខ្លួនព្រើតនឹកអរព្រួចចាំងុ! ទារកនេះចេះនិយាយហើយតើ! ហើយរត់បានតាមផ្លូវការផង? ។ មិនយូរប៉ុន្មានខ្ញុំបាទក៏បានផ្ញើសំបុត្រមកសម្ញាក់ខ្ញុំចុះឈ្មោះ ជាទស្សនាវដ្ដីទារកមានសំដីពីរោះ ផ្ញើទៅឲ្យតាំងពីពេលចូលឆ្នាំ១៩៥៥ម៉្លេះ ហើយរង់ចាំមើលមុខមាត់ទារកនេះជាយូរហើយប៉ុន្តែមិនចេះឃើញសោះ ។ លុះដល់ខែទី៤នេះទើបលេចមុខទារកទៅដល់ ។ ធុ! គួរឲ្យអាណិតអាសូរដល់ទារកពេក កាលបើចូលដល់ខែត្របាត់ដំបងហើយ មិនហ៊ានឹងចេញមុខទៅដល់ឃុំ

វត្តតាមិមទៀត ទៅដល់ហើយមានគេយកទៅចោល នៅតៀមស្រាចិនទៀត ដេកនឹងតៀមចិនចំនួន៣ , ៤យប់ ទើបតែខ្ញុំឃើញប្រភារកប្រឡាក់ដីឲ្យស្រមក អត់បាយក្រហាយទឹក រហែកអស់ទោសាវាដើរច្រាត ទ្រូងទទេ ៗ ហើយមិនឃើញមុខទារកច្បង(លេខ១) ទេ ទៅឃើញឯទារកប្អូនបន្ទាប់ទៅវិញ (លេខ២) ៗ ឱ! ទារកអើយ អ្នកកម្មអ្វីកអកុសលម៉្លេះ! មានរូបកើតជាទារកនឹងគេដែរ ម្តេចក៏រងទុកវេទនាម៉្លេះ

ឱ! ខ្ញុំបាទ , កាលបើទឹកឃើញដល់ទារកនេះកាលណា ខ្ញុំអាណិតលោកជាប្រធានសមាគមខ្លាំង លោកខំតញ្ញូតែនៅពេលដែលធ្វើសន្និសីទម្តង១ថា : " ទារកនេះបានចាប់បដិសន្ធិហើយប្រសូតចេញពីផ្ទៃហើយ ប៉ុន្តែទារកនេះមិនសូវមានសាច់ឈាមធាត់ធំល្អទេ បេះតែកើតរោគរីងរៃស្គាប់មួង ហើយ ឥឡូវប្រសូតចេញមួងទៀតហើយ សូមលោកអ្នកអានជួយបំប៉នបំណាំ អាហារ (ដោយជួយចុះជាវឲ្យផង " ៗ

ឱ! សរសេតពាំពេងនៃលោកប្រធានសមាគម កាលបើខ្ញុំលើកទស្សនាវដ្តីអានកាលណា កាលនោះខួរក្បាលរបស់ខ្ញុំនឹកឃើញហើយចាំជាក់ដល់មុខលោកទៀត ៗ

រឿងនេះ បើតាមយោបល់របស់ខ្ញុំបាទថា សុំឲ្យលោកប្រធាននៃសមាគម ធ្វើសេចក្តីអំពាវនាវដល់អតីតសិស្សដោយចំណោះឲ្យជួយចុះជាវ ៗ ព្រោះថា អតីតសិស្សយើង ដែលបានទទួលឋានៈជាពាជការណាមួយ ហើយមានសមត្ថភាពក្នុងការចុះជាវបានដោយគ្រាន់ជាទីកំសាន្តជាងការដប់លៀងនៅភោជនីយស្ថានធំៗម្តង ១ ៣ ឬ ៤រយរៀលមួយកែត មួយ ចំតែតប៉ុណ្ណោះ ៗ

លទ្ធផលនៃការចាក់ចងបែបនេះ ធ្វើឲ្យជនជាតិយើងចេះចូលចិត្តអាន សៀវភៅ ដូចជនជាតិក្នុងពិភពលោក ចេះស្រឡាញ់ផ្ចិតច្បាប់ជាងជម្ងឺសង្គម ដែលអាណានិគមនិយម បានសាបព្រួសមកជាយូរឆ្នាំហើយផង ៗ ធ្វើបែបនេះហាក់ដូចជាថ្នាំទាញជម្ងឺសង្គម ឬតព្យាបាលជម្ងឺឲ្យជាបន្តិចម្តង ៗ

មួយទៀត អ្នកអានទស្សនាវដ្តីជនបរទេសគេមិនចៀនដល់តួទស្សនាវដ្តីយើងផង ដល់អ្នកអានផង ៗ អ្នកណាអានទស្សនាវដ្តីយើងគេហៅ យើងអាចារ្យមិនដឹងជានៅស្ពាយយាមអានតែធម៌ធ្វើអ្វី ? ៗ ពាក្យនេះសូមលោកជួយកែរកនេះឲ្យបានខ្លះៗ កុំឲ្យគេថា "អ្វីៗ និយាយតែពីធម៌ សូមលោកជួយកែរឿងនិពន្ធនេះកុំឲ្យដូចគេថានោះពេកដោយនិពន្ធឲ្យមានផ្សំលោកច្រើន

សេចក្តីនេះ ខ្ញុំបាទជាអតីតសិស្សហើយមានទឹកចិត្តអាណិតដល់ទារកនេះខ្លាំងណាស់ កាលបើគនិយាយខ្លាំងៗនឹងគ្រូចៀតហើយ បើមិនធ្វើព្រះទគថាយើងថ្ងូរបើមិនស្តីគេថាយើងគ, ម្ល៉ោះហើយតវែតតខ្លះស្ងាត់ខ្លះដំរាបមកលោកឲ្យជួយគិត គឺសូមឲ្យលោកជួយតៀនឲ្យគេបញ្ជូនទៅឲ្យរហាស់ ហើយឲ្យ

ទារកស្លៀកពាក់ឲ្យស្រួលបួលកុំឲ្យយកទៅប្រោស ពេលទៅតៀមមិនដូចពេលមុនៗ ។ខ្ញុំបាទនៅឯនាយនោះ មានសេចក្ដីសង្ឃឹមនឹងទទួលអំណរគុណលោកយ៉ាងក្រៃលែងថា លោកមុខជានឹងជួយ ផ្សាយសេចក្ដីនេះដល់សមាគមដែលជាមាតាបិតារបស់យើងឲ្យបានជ្រាបរឿងនេះឲ្យទាន ។ ហើយនឹងសង្ឃឹមលោកថានឹងមិនប្រកាន់ទោសចំពោះលិខិតនេះដែលជាប្អូនរបស់លោកប្រសូតចេញពីខួរជាមួយឡើយ ។

សេចក្ដីគួរពុំគួរសូមអភ័យទោស

ហត្ថលេខា

ឆត - ចៅ

---

## ការសិក្សាប្រទេសជប៉ុន (ត)

សាលារៀន "តេឡាខូយ៉ា" នេះបានក្លាយទៅជាស្ថានបឋមសិក្សាក្នុងកាលជាលំដាប់តមក សាលារៀនប្រភេទនេះ បែកមែកសាខាផ្សាយចេញទៅយ៉ាងរហាស់ ហើយបានក្លាយទៅជាកន្លែងសិក្សារបស់អ្នកចម្បាំងសាមូរ៉ៃ រហូតដល់ប្រជារាស្ត្រសាមញ្ញ ។

ព.ស. ២៤១០ ជាឆ្នាំដែលជប៉ុនឈប់លើកលែងប្រើរបៀបបែបប្ចូគុន ចំណែកព្រះមហាក្សត្រិយ៍ជប៉ុនទ្រង់មានព្រះរាជអំណាចសិទ្ធិដាច់ខាត ដូចដែលធ្លាប់មានមក ហើយពីពេលមុននោះ, រដ្ឋាភិបាលក៏បានផ្លាស់ប្តូររបៀបការគ្រប់គ្រងជាថ្មី ឲ្យទាន់តាមសម័យនិយមឡើង , ហើយទ្រង់បានតាំងក្រសួងសិក្សាឡើងក្នុង ព.ស. ២៤១៤

កាលថ្ងៃទី១៤ ខែមិនា ព.ស. ២៤១១ ព្រះចៅចក្រពត្តិមេអ៊ិយ បានទ្រង់ ប្ដេជ្ញាដែលជាមូលដ្ឋានក្នុងការកសាងជាតិជប៉ុនថ្មី មានសេចក្ដីដូចតទៅនេះគឺ

១ – ទ្រង់ចាត់ឲ្យមានស្ថានប្រឹក្សាការផែនដី ហើយទ្រង់គ្រប់គ្រងប្រទេសដោយអាស្រ័យ ប្រជាមតិជាធំ ។

២ – ជនគ្រប់ជាន់គ្រប់ថ្នាក់មិនចំពោះជាន់ខ្ពស់ ឬជាន់ទាបត្រូវតែរួមចិត្តរួមគំនិតគ្នា ប្រកបកិច្ចការរបស់ប្រទេសជាតិ ។

៣ – អ្នករាជការទាហាននឹងអ្នករាជការស៊ីវិល ត្រូវជួយសង្គ្រោះដល់គ្នា ឯពពួកប្រជាជនក៏ត្រូវប្រព្រឹត្តសេចក្ដីស្មោះត្រង់ ចំពោះប្រទេសជាតិដូចគ្នាដែរ

៤ – នឹងកែប្រែចារិតប្រពៃណីខ្លះ ដែលផុតសម័យនិយមហើយនោះ ហើយនឹងជួយលើកតម្កើងឋានៈ របស់ប្រជារាស្ត្រឲ្យមានឋានៈ ខ្ពង់ខ្ពស់ឡើង ។

៥ – នឹងផ្សាយនូវសិល្បវិជ្ជា ការផ្សេង ៗ របស់នានាជាតិឲ្យបានដល់ពួកប្រជារាស្ត្រ , តអំពីនោះមករដ្ឋាភិបាលបានចាប់យកនូវសេចក្ដី ប្ដេជ្ញាខាងនេះប្រកាន់ខ្ជាប់ ទុកជាគោលការណ៍យ៉ាងសំខាន់ក្នុងការ

ចាត់របៀបការសិក្សារបស់ជនជាតិជប៉ុនសម័យថ្មីមក អំពីរដ្ឋាភិបាលជប៉ុនក្នុងសម័យនេះបាន. បើកទ្វារទទួលជនបរទេស នោះវប្បធម៌របស់ពួកអឺរ៉ុបនិងអាមេរិកក៏បានហូរចូលទៅក្នុងផែនដីប្រទេសជប៉ុនជាច្រើនយ៉ាង, ការសិក្សាតាមរបៀបសម័យថ្មីរបស់ជប៉ុនក៏បានឈានទៅរកសេចក្តីចំរើនឡើងជាលំដាប់ ។

ចាប់តាំងពីសម័យដែលព្រះមហាក្សត្រិយ៍មានព្រះរាជសម្បូរណាញ្ញាសិទ្ធិពេញទីមក ( Restoration ) រដ្ឋាភិបាលថ្មីក៏បានចាត់របៀបការសិក្សារបស់ប្រជាជនយ៉ាងប្រញាប់ ដើម្បីពង្រីកការសិក្សាឲ្យបានធំទូលាយឡើង មានការសាងសង់សាលារៀនផ្សេងៗដែលតាំងនៅក្នុងក្រុង យេដូ ឲ្យសមទៅតាមសម័យ, ក្រោយអំពីនេះក៏បានចាត់តាំងមហាវិទ្យាល័យអាម្ប៉េរីយ៉ាល់ (Impérial) ឬហៅថាចក្រពត្តិមហាវិទ្យាល័យឡើងឯក្រុងតូក្យូ, គ្រឹះស្ថានសិក្សាជាន់ខ្ពស់នេះ ជាមូលដ្ឋាននៃវប្បធម៌និងការសិក្សាសិល្បវិទ្យាផ្សេងៗ បណ្តាគ្រឹះស្ថានសិក្សានានា ក្នុងរាជអាណាចក្រជប៉ុនត្រូវឡើងត្រង់ចំពោះមហាវិទ្យាល័យនេះតែមួយ ។

នៅក្នុងខែកក្កដា ព.ស.២៤១៤ រដ្ឋាភិបាលបានក្រសួងសិក្សាធិការដែល ជាអគ្គការណ៍គ្រប់គ្រងនិងថែទាំនៃការសិក្សារបស់ជាតិឡើង លុះដល់ខែសីហា ព.ស ២៤១៥ ក្រសួងសិក្សាធិការបានប្រកាសអំពីរបៀបការសិក្សារបស់ជាតិដែលជាមូលដ្ឋាននៃបទបញ្ញត្តិ ដែលមានការទាក់ទង ក្នុងការសិក្សារបស់ប្រជាករជប៉ុនក្នុងបច្ចុប្បន្នសម័យ ។

ក្នុងពេលដែលប្រកាស របៀបការសិក្សានិងជាក់បទបញ្ញត្តិច្បាប់ដែលទាក់ទងក្នុងការសិក្សានោះ ក៏មានព្រះរាជឱង្ការរបស់ព្រះចៅចក្រពត្តិ ប្រកាសដែលមានសេចក្តីសំខាន់ដូចតទៅនេះថា: ចាប់តាំងអំពីពេលដែលបានចេញប្រកាសនេះរាល់ៗឆ្នាំដែលផុតពីសម័យវិស្សមកាល និងត្រូវចូលរៀនជាថ្មីទៀតនោះ ត្រូវតែធ្វើពិធីអានប្រកាសព្រះរាជឱង្ការ ច្បាប់នេះជាដរាបតាមចារីតសាសនា គ្រប់គ្រឹះស្ថានសិក្សាក្នុងព្រះរាជ-អាណាចក្រទាំងមូល, តអំពីនេះការសិក្សានិងការអប់រំត្រូវឲ្យមានគ្រប់គ្រួសារ នៅក្នុងភូមិនីមួយៗមិនត្រូវឲ្យគ្រួសារណាល្ងង់ឡើយ ឯអ្នកដែលនៅក្នុងគ្រួសារនោះៗ ក៏មិនត្រូវឲ្យរួមជនណាម្នាក់ទោះបីភេទស្ត្រី ឬបុរសមិនបានសិក្សារៀនសូត្រជាដាច់ខាត គឺត្រូវតែឲ្យរៀនគ្រប់ៗគ្នា ។

សេចក្តីក្នុងព្រះរាជឱង្ការប្រកាសច្បាប់នេះ រដ្ឋាភិបាលបានធ្វើអត្ថាធិប្បាយជស់សេចក្តីបំណង នៃនយោបាយការសិក្សារបស់ជាតិ ដែលត្រូវឲ្យបណ្តាសាលារៀនទាំងឡាយ ។

តាំងជាមូលដ្ឋាននៃការផ្សាយសព្វៈវិទ្យាការនិងសិល្បសាស្ត្រដែលជាគុណប្រយោជន៍ក្នុងអាជីវៈភាព

ជួយឧបត្ថម្ភជនឲ្យមានសមត្ថភាព ទទួលតំណែងនាទីក្នុងសង្គម, និងឲ្យមានសមត្ថភាពចាត់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ហើយអាចនាំមកនូវសេចក្ដីចំរើនរុងរឿងដល់ប្រទេសជាតិ និងរូបអ្នកដែលបានសិក្សារៀនសូត្រនោះ ។

ចំណែកបញ្ហារៀងសាលារៀននោះ របៀបការសិក្សារបស់ជាតិក៏បានចាត់គ្រោងការមុន ដែលនឹងសាងសាលារៀនបឋម, មធ្យម, ឧត្តមសិក្សាពេញព្រះរាជអាណាចក្រហើយ ។

របៀបការសិក្សានេះ បានចំឡងតាមរបៀបការសិក្សារបស់បារាំងសេស ដោយបានប្រគប់ការផ្ដើរឲ្យរាជការភាគកណ្ដាល (Centralized) គឺក្រសួងសិក្សាធិការជាអ្នកគ្រប់គ្រងនិងមើលថែទាំ សាលារៀនទាំងអស់ក្នុងព្រះរាជអាណាចក្រ រហូតដល់ការចាត់មេរៀនមេទន្ទេញផង, ការដែលប្រគល់អំណាចពេញទីឲ្យរាជការបរិហារក្នុងភាគកណ្ដាលនេះ ក៏ដើម្បីកសាងសេចក្ដីសាមគ្គី ការព្រមព្រៀងគ្នាឲ្យទៅជាធុងមួយប៉ុណ្ណោះ របៀបនេះគឺរបៀបដែលនៅក្រោមការគ្រប់គ្រងរបស់ក្សត្រិយ៍ ដែលគ្រប់គ្រងនគរចំណុះនោះ ឯងប្រទេសជប៉ុនបានត្រូវញែកចេញជារដ្ឋតូច ៗ ឬហៅថាប្រទេសរាជផ្សេងៗប្រហែលជា៤០០ដល់ ២៧០នគរមកជាយូរអង្វែងប្រហែលជា៧០០ឆ្នាំ លក្ខណៈសំខាន់នៃរបៀបការសិក្សារបស់ជាតិនេះ គឺបំណងចង់ចងភ្ជាប់ការសិក្សាចាប់តាំងពីសាលារៀនបឋម រហូតដល់មហាវិទ្យាល័យ ឲ្យជិតដិតស្និទ្ធស្នាលមានដួងចិត្តតែមួយ (គឺឲ្យស្រឡាញ់ប្រទេសជាតិ) ហេតុនោះទូទៅក្នុងព្រះរាជណាចក្រ ទើបមានសាលារៀនបែបបឋម-សិក្សាមានរបៀបតែមួយ អ្នករៀនដែលបានរៀនសម្រេចមធ្យមសិក្សាហើយ ក៏មានឱកាសរៀនបំពេញវិជ្ជាក្នុងថ្នាក់ខ្ពស់ឬមហាវិទ្យាល័យតទៅរបៀបដែលចាត់ការសិក្សារបស់ជប៉ុន បានបង្ខំឲ្យទាន់ពេលដែលជប៉ុននឹងបានចាត់របៀបការគ្រប់គ្រងបែបប្រ-ជាធិបតេយ្យ គឺប្រកាសប្រើរដ្ឋធម្មនុញ្ញកាលពីថ្ងៃ១១ កុម្ភៈ ព.ស. ២៤៣២ តាំងតែពីពេលនោះមកឧត្តមគតិនៃលទ្ធិប្រជាធិបតេយ្យនោះ គេក៏បាននាំយកមកប្រើក្នុងការទំនុកបម្រុងការសិក្សារបស់ប្រជាករជប៉ុនឲ្យមានរបៀបរៀបរយល្អឡើង, ការដែលប្រគល់អំណាចឲ្យរដ្ឋាភិបាលកណ្ដាល ឬន័យមួយវិញទៀតជារាជការបរិហារការ កណ្ដាលនោះជាអ្នកចាត់របៀបនយោបាយការសិក្សាជាតិ និងជាអ្នកចាត់ការសិក្សាតាមផែនរបស់ប្រជាធិបតេយ្យនេះ ក៏បានធ្វើឲ្យការសិក្សារបស់ជប៉ុនមានដំណើរទៅកាន់វឌ្ឍនភាពយ៉ាងក្រៃលែង ហើយអាចហុចឲ្យសារត្ថប្រយោជន៍ធំធេងទូលាយដល់ឧទ័យប្រទេស ដរាបមកដល់សម័យសព្វថ្ងៃនេះ ។

តាមគ្រោងការណ៍សិក្សាជាតិដែលដាក់បទបញ្ញត្តិ

មានការទាក់ទងនឹងការសិក្សា ព. ស. ១៤១៥នោះ បានញែកភាគនៃការសិក្សានោះទៅជា ៨ ខែត្រក្នុងមួយខែត្រ ៗ សុទ្ធតែមានមហាវិទ្យាល័យមួយ ៗ ដែលចាត់ទុកថាជារបស់សំខាន់នៃការសិក្សា;

តែមហាវិទ្យាល័យ ដែលតាំងនៅក្នុងខែត្រមួយនោះញែកប្រភេទជាខែត្រតូចៗរាយរង់ទៅ ៣២ ខែត្រ, ក្នុងខែត្រតូច ៗ រាយរង់នេះគឺមួយខែត្រ ៗ មានសាលាមធ្យមសិក្សាមួយ ៗ ក្នុងសាលរៀនមធ្យមសិក្សាមួយ ៗ នោះ មានញែកប្រភេទនៅជាសាលារៀនបឋមសិក្សា ២១០ សាលារៀនឯទៀតត្រូវនៅក្នុងការទំនុកបម្រុងរបស់ខ្លួនឯងបង្កើតឡើង ។

លុះមកដល់ពុទ្ធសករាជ ២៤២៩ រដ្ឋាភិបាលជប៉ុនបានរៀបចំរបៀបបទបញ្ញត្តិដែលមានការទាក់ទងក្នុងការសិក្សាឲ្យចុះសម្រុង តាមរបៀបការសិក្សារបស់អាល្លឺម៉ង់, នៅក្នុងឆ្នាំជាមួយគ្នានោះរដ្ឋាភិបាលបានកែផ្លាស់ប្តូររបៀបបទបញ្ញត្តិ ដែលមានការទាក់ទងនឹងមហាវិទ្យាល័យ, សាលារៀនមធ្យមសិក្សា សាលារៀនបឋមសិក្សា និងសាលាគរុកោសល្យថ្មីទាំងអស់ ។

តមកដល់ ព.ស. ២៤៤៣ រដ្ឋាភិបាលកែខបន្ថែមបន្ថយបទបញ្ញត្តិ ដែលមានការទាក់ទងនឹងសាលារៀនទេកនិក, សាលារៀនមធ្យមនារី និងរៀនហ្វឹកហាត់វិជ្ជាជីវៈ ឲ្យសមរម្យទៅតាមកាលសម័យឡើង ។

ក្រោយ ព.ស. ២៤៤៦ មកសាលាវិទ្យាល័យផ្សេង ៗ បានពង្រីកហើយចំរើនរុងរឿងឡើងយ៉ាងរហ័សអស្ចារ្យ, កាលមហាយុទ្ធសង្គ្រាម (១៩១៤–១៩១៨) ក្នុងអឺរ៉ុបបានចូលផុតទៅហើយ នោះសាលារៀនថ្នាក់មធ្យម និងសាលារៀនគ្រប់ជាន់–ថ្នាក់ ដែលមានវិទ្យាឋានៈ ធៀបស្មើគ្នានឹងមហាវិទ្យាល័យ ក៏បានចំរើនចំនួនឡើងជាលំដាប់ ។

ក្នុងសម័យមួយជាមួយគ្នានោះ អង្គការណ៍នៃការសិក្សាផ្សេង ៗ របស់ឯកជនដែលនៅក្រៅការថែទាំរបស់រដ្ឋាភិបាលកណ្តាល ក៏ចូលមកនៅក្នុងអំណាចបរិហាររបស់ក្រសួងសិក្សាធិការ តាមគោលការណ៍គ្រប់គ្រងរបស់មធ្យភាគ ។

## នយោបាយការសិក្សារបស់ជាតិ

នយោបាយការសិក្សារបស់ជប៉ុនបានប្រកាន់ម៉ាំត្រង់គោលចារឹកគឺចារឹតប្រពៃណី ជារបស់សំខាន់ទីបំផុតរបស់ប្រទេស សម្រាប់ធ្វើឲ្យប្រទេសឈានដើរទៅរកវឌ្ឍនភាពបានដោយឆាប់រហ័ស ។ ចារឹតប្រពៃណីរបស់ពួកជនអាទិត្យុទ័យ (ជប៉ុន) មានការសម្ពន្ធទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងចារឹតប្រពៃណីរបស់ជនជាតិអាស៊ីទូប ជប៉ុនទទួលយកប្រពៃណីខ្លះដែលសមនឹងចិត្តគំនិត របស់ខ្លួនមកអំពីប្រទេសអឺរ៉ុបនិងអាមេរិក, ក្រៅអំពីការប្រកាន់ម៉ាំក្នុងចារឹតប្រពៃណីនោះ.. សារៈសំខាន់របស់នយោបាយការសិក្សាបានផ្អែកជាប់ទៅនឹង ព្រះបរមរាជ

ឱង្ការ ដែលមានពណ៌នាអំពីការសិក្សារបស់សម្ដេចព្រះចក្រពត្តិ ទ្រង់ព្រះនាម "មេអ៊ិយ៉ិ" ដែលព្រះអង្គបានត្រាស់ ទុកកាលពីថ្ងៃទី ៣០ តុលា ព.ស. ២៤៣៣ តាមសាលារៀនផ្សេងៗ ទូទៅក្នុងព្រះរាជអាណាចក្រជប៉ុន មានតាំងសំណៅព្រះបរមរាជឱង្ការច្បាប់នោះទុកសម្រាប់អាន ប្រកាសប្រាប់ក្នុងបន្ទប់ទីប្រជុំរបស់សាលារៀនក្នុងថ្ងៃទី ៣០ តុលារាល់ៗឆ្នាំ ជាការដាស់តឿនក្រើនរំលឹកដល់ជាតិជប៉ុន ឲ្យភ្ញាក់គំនិតប្រញាប់កសាងប្រទេស មាតុភូមិឲ្យបានរុងរឿងឡើង ដើម្បីចាត់ការសិក្សារបស់ពលរដ្ឋ ឲ្យមានរបៀបទៅតែមួយដូចៗគ្នា ទូទៅក្នុងរាជអាណាចក្រជប៉ុន រដ្ឋាភិបាលកណ្ដាលជាអ្នកមើលថែទាំទុកបម្រុង ការសិក្សារបស់ជាតិ ដែលរដ្ឋាភិបាលដំណើរយ៉ាងនេះក៏ដើម្បីនឹងរក្សាចារីតប្រពៃណីខ្ញុំដែលជាគ្រឿមតិករបស់បុព្វបុរសនោះទុកឲ្យគង់វង្ស, ហើយនឹងប្រឹងប្រែងទំនុកបម្រុងការសិក្សារបស់ជាតិឲ្យសមរម្យ ទៅតាមការវិវត្តន៍ប្រែប្រួលនៃការសិក្សារបស់នានាជាតិក្នុងការដែល រដ្ឋាភិបាលនឹងចូលទៅគ្រប់គ្រងថែទាំបណ្ដាសាលារៀនទាំងឡាយយ៉ាងម៉ឺងម៉ាត់ តាមក្នុងបទបញ្ញត្តិចាត់របៀបការសិក្សារបស់ជាតិយ៉ាងច្បាស់លាស់ ។

របបវិធីការសិក្សារបស់ជប៉ុន ញែកចេញទៅជា ៣ ថ្នាក់គឺ ១ ថ្នាក់បឋមសិក្សាកំណត់វេលារៀន ៦ឆ្នាំ ការសិក្សាថ្នាក់នេះជាការសិក្សាបង្ខំ ដូចគ្នានឹងបឋមសិក្សារបស់ប្រទេសយើងដែរ (មានត)



## ចៅស្មែនទន្សាយធ្វើដំណើរជុំវិញពិភពលោក

(តមកពីឆ្នាំ១៩៥៤)

### ២ - ប្រទេសឥណ្ឌា

សូមអភ័យទោស! ចៅស្មែនទន្សាយត្រូវធ្វើដំណើរទៅសហរដ្ឋអាមេរិក តែដោយអាកាសយាន

ខ្ញុំក៏ត្រូវត្រឡប់មកមើលប្រទេសឥណ្ឌាសិន ចៅស្វែងទន្សាយបានធ្វើដំណើរចេញពីកាតមណ្ឌូ, ព្រះរាជធានីនៃប្រទេសណេប៉ាល់ឆ្ពោះមក

កាន់ទីក្រុងញូវដែលហ៊ី (ប្រទេសឥណ្ឌា) តាមអាកាសយានពិសេស ។ ចៅស្វែងទន្សាយបានទៅឈប់នៅវត្តអាសោការាម វត្តដែលព្រះភិក្ខុវិធម្មរៈ (បេល្ហុក) គង់នៅ ។ នៅទីនោះ ចៅស្វែងទន្សាយបានទៅជួបនឹងភិក្ខុខ្មែរ ៥ រូបដែលសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត, ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយនៅប្រទេសកម្ពុជា ព្រមទាំងពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋបានបញ្ជូនឲ្យនិមន្តទៅជាមួយ ព្រះមហាថេរវិធម្មវរៈ ដើម្បីនឹងសិក្សារៀនសូត្រ ភាសាហិណ្ឌី សំស្ក្រឹត នឹងព្រះពុទ្ធសាសនា ។

ទីក្រុងញូវ-ដែលហ៊ី ជាព្រះរាជធានីនៃប្រទេសឥណ្ឌាតាំងនៅច្រាំងខ្ពស់នៃទន្លេគង្គា មានប្រជាជនប្រហែល ៤០០.០០០នាក់ ។ ក្នុងចំនួនទាំងអស់នេះ មានជនជាតិមហាម៉ាត់ ១១៥.០០០នាក់ ។ ទីក្រុងនេះ ជាទីក្រុងទំនើបមានកំពែងព័ទ្ធជុំវិញហើយ មានសិលាគ្រឹះសង់ទៅតាមវិថីតូច ៗ បង្អៀតមានគេហដ្ឋានសំខាន់ព្រះវិហារមហាម៉ាត់, ប្រាសាទគូតាប់ដែលសង់ពីសតវត្សទី១៣, មហាប្រាសាទមុង្គូលសាងពីគ.ស. ១៦៣៨ ទៅដល់១៦៤៨នឹងគ្រឹះហារសម័យថ្មីដែលលោកស៊ិរ.ដ.លុតជិន្ស (Sir-D. Lutjens) បានសង់ទីក្រុងនេះជាមជ្ឈដ្ឋានឧស្សាហកម្មនឹងពាណិជ្ជកម្ម (គុជខ្យង, កក, ប្រាក់, ស្ពាន់, ប៉ាក់. ត្បាញសំពត់កប្បាស, ថាំជក់: ស្ក...ល...។

ទីក្រុងនេះស្ថាបនាតាំងពី គ.ស. ១៦៣១ដោយមហារាជសាហ៍, ឌ្យាហាន (Chah -Djahân) ជាអ្នកកសាងនៅខាងជើងប្រាសាទទីក្រុងចាស់ ១ ដែលគ្មានអ្នកណាដឹងបានស្រាវជ្រាវស្គាល់នូវបុព្វហេតុ ។ ទីក្រុងជាច្រើននេះពីដើមមានប្រជាជនស្ថិតនៅក្នុងករច្រើនក្រោមភាពមានភោគទ្រព្យ, ហើយស្ថិតនៅរាជធានីប្រទេសឥណ្ឌាមកដល់គ..ស.១១៩៣ ។ តែមកដល់ គ.ស. ១៣៩៣ មេទ័ពមហារាជសង់សិសកាន់ នាមតាមែរឡង់ បានវាយដណ្ដើមយកបាន ។ ក្នុងពេលនោះ ប្រទេសឥណ្ឌា ក៏បានលើករាជធានីមកតាំងនៅទីក្រុងអគ្រា (Agra) ។ លំដាប់តមកពួកអង់គ្លេសបានវាយយកទីក្រុងដែលហ៊ីនេះបាន ក្នុង គ.ស. ១៨០៦ ហើយក៏កំណត់ទីក្រុងនេះជាព្រះបរមរាជវាំងមហារាជមុង្គូល គ.ស. ១៨៥៧, ទីក្រុងនេះធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកទាហាន ដែលពួកអង់គ្លេសបានជួលទៅធ្វើការសឹក (Cipayea) ។ ទីក្រុងនេះបានវិលត្រឡប់ទៅជាព្រះរាជធានី ប្រទេសឥណ្ឌាវិញតាំងពីគ.ស. ១៩១១ ។

ចៅស្វែងទន្សាយ បានទៅជួបនឹងនាយពាណិជ្ជ

ហិណ្ឌូម្នាក់ ពីដើមធ្លាប់នៅទីក្រុងភ្នំពេញ ឈ្មោះអាម៉ាត់ស៊ុនៗ នាយពាណិជ្ជនេះបានលះបង់គេហដ្ឋាននៅព្រះរាជធានី ប្រទេសកម្ពុជាប្រគល់ឲ្យបុត្រច្បងរបស់គាត់នាមអាលីម៉េត កាន់កាប់ស្នងគាត់តមកៗ ឯចំណែកខ្លួនគាត់ក៏មកនៅទីក្រុងដែលហ្លីជាមួយនឹងកូនស្រីគាត់ម្នាក់ៗ លោកអាម៉ាត់ស៊ុន ក៏បានស្គាល់ជាក់ច្បាស់នូវចៅស្នងខនឡាយ បាននាំចៅនេះទៅកាន់គេហដ្ឋានរបស់គាត់បរិភោគបាយដោយមេត្រីៗ លុះដល់ពេលល្ងាចចៅស្នងខនឡាយ ក៏សាកសួរលោកអាម៉ាត់ស៊ុនអំពីភូមិសាស្ត្រ, ប្រវត្តិសាស្ត្រ, សាសនាជាតិ, សង្គម, សេដ្ឋកិច្ចប្រទេសឥណ្ឌៀដូចតទៅនេះ

លោកអាម៉ាស៊ុនក៏ជំរាបចៅស្នងខនឡាយថា:

ប្រទេសឥណ្ឌៀបូរាណកាល មកដល់គ.ស១៩៤៥ មានវិសាលភាព៤.៦៨០.០០០គីឡូម៉ែត្រទ្វេគុណ នឹងមានប្រជាជន៣៩០លាននាក់ ៗ

តាំងពីថ្ងៃទី២០ ឧសភា ១៤៩៨ ដែលលោកនាវាចរ ពរទុយគេ នាមវ៉ាស្កូដឺគាម៉ា បានចូលមកដល់ទីក្រុងកាលីគុត (ភូមិភាគម៉ាឡាបារ) រហូតមកដល់ គ.ស.១៩៤៩, ដែលប្រទេសនេះ ត្រូវអង់គ្លេសបែងចែកជាពីរគឺ: សាធារណរដ្ឋអ៊ីនឌៀន នឹងប្រទេស ប៉ាគីស្ថាន ប្រទេសនេះមានភូមិភាគខ្លះនៅក្នុងកណ្ដាប់ដៃពួកពរទុយគេខ្លះនៅក្នុងអាណានិគមបារាំងខ្លះនៅក្នុងអនិស្សរភាព ឬ កុម្មង់វែលព្រិតណ្ណិ ៗ

សាធារណរដ្ឋអ៊ីនឌៀនឬភារត មាន២លាន ៨៥៥.០០០ គីឡូម៉ែត្រទ្វេគុណ ; មានប្រជាជន ៣៤៦ លាននាក់ ៗ ប្រទេសប៉ាគីស្ថានមាន៩០០.០០០គីឡូម៉ែត្រទ្វេគុណ, មាន៧៤ លាននាក់ ៗ

សាធារណរដ្ឋអ៊ីនឌៀនដែលមានព្រះរាជធានីតាំងនៅទីក្រុងញូវ, ដែលហ្លីគឺជារដ្ឋសម្បូណ៌ខាងក្សេត្រកម្មនឹងកសិកម្ម ៗ ក្នុង២នៃភាគ៣, ប្រជាជនរស់ដោយសារផលានុផលគឺ ស្រូវសាលី, ពោតថ្វូ, សណ្ដែកដី, កប្បាស, អំពៅ, តែ, ផ្លែឈើបន្លែ, ថ្នាំជក់····ល·· ដោយមានធារាសាស្ត្រកសិកម្ម ៗ ឯដីណាដែលគ្មានទឹកគេអាចបង្ហូរទឹកចូលទៅដល់ស្រែចំការស្រោចស្រូវដំណាំបាន ៗ

ក្រៅពីផលានុផលខាងលើ ប្រទេសនេះមានបសុសត្វ ១៣៧ លានក្បាល ៗ មានប្រជាជនដោយភាគច្រើន ៗ បរិភោគរុក្ខជាតិ, មិនបរិភោគសាច់, ទឹកដោះគោមិនសូវមានដោយបរិបូណ៌ ៗ ចំណែកខាងឧស្សាហកម្ម មានលោហធាតុដែក, សំណប៉ាហាំង, ស្ពាន់ស, ធ្យូងថ្ម ៗ ល ៗ ឧស្សាហកម្មខាងរាយនភណ្ឌមានធ្វើនៅខេត្តស្រុកឃុំ· មានការធ្វើជី, ស៊ីម៉ង់, ក្រដាស, រថយន្ត, អាកាសយានជាដើម ៗ មានការដឹកនាំចេញ, សំណប៉ាហាំង តែ, ថ្នាំជក់, គ្រឿងទេសគ្រាប់រុក្ខជាតិធ្វើប្រេង, កប្បាស, ឧណ្ហាម័យ, ស្រូវសាលី, សំពត់កប្បាស .... ល .... ទៅប្រទេសឡាក្រង់ប្រឺតាញ,

បើពិនិត្យតាមភូមិសាស្ត្ររូបភាពឥណ្ឌា, ប្រទេសនេះមាន៣ស្ថានគឺៈ ភ្នំហេមាល័យ១, វាល-ឥណ្ឌូ-គង្គា១, ឧបទ្វីបដេកាន់១ ។ ភ្នំហេម៉ាល័យជាភ្នំខ្ពស់ជាងគេ; មានភ្នំមួយហៅថាអេវើរេសប៊ុគ្គូរ៉-សង់ការ មានកំពស់ជាង៨គីឡូម៉ែត្រ ហើយមានជ្រោះជាច្រើនព័ទ្ធជុំវិញប្រមូលទៅជារដ្ឋមួយ នាមថារដ្ឋកាស៊ីមីរ។ រដ្ឋនេះជាបឹងមួយធំហើយរើងទឹកមានដីល្បប់មកពីថ្មភ្នំភ្លើងតែមានផលភាពដាំអ្វីក៏បាន ។ អាកាសមានភាពប្លែកៗគ្រប់កន្លែង ។

វាលឥណ្ឌូ-គង្គា មានដីល្បប់ជាច្រើនទៅពីឈូងសមុទ្រអូមង់ទៅដល់ឈូងសមុទ្របង្គាល ។

ឧបទ្វីបដេកាន់គឺជាដីសល់ពីដីចាស់ដែលជាប់គ្នាទៅនឹងទ្វីបអាហ្វ្រិកនិងប្រទេសអូស្ត្រាលី ។

បើតាមខាងផែនយោបាយ, ប្រទេសនេះពីកាលមុនគ.ស. ១៩៤៩ ត្រូវស្ថាបនាឡើងដោយបញ្ញត្តិអាក់ត៍(Act)១៨៥៨ ។ នៅទីក្រុងឡុងដ្រ៍ ប្រទេសអង់គ្លេស មានអគ្គលេខាធិការប្រទេសឥណ្ឌាម្នាក់ ដែលជាមន្ត្រីធ្វើការរួមជាមួយនឹងសមាជិកគណៈរដ្ឋមន្ត្រី ប្រទេសអង់គ្លេស អគ្គលេខាធិការនេះ មានក្រុមប្រឹក្សាប្រទេសឥណ្ឌាធ្វើការអមជាមួយផង ។ ទីក្រុងដែល្ហី, ព្រះរាជ-ធានីប្រទេសឥណ្ឌា ហើយទីក្រុងមួយទៀតហៅថា «ស៊ិមឡា» ទីនៅនៃឧបរាជឥណ្ឌាក្នុងវស្សានរដូវ ។ ឧបរាជនេះត្រូវតែងតាំងក្នុងរយៈវេលា៥ឆ្នាំ ហើយមានក្រុមប្រឹក្សានីតិបញ្ញត្តិ និងនីតិប្រតិបត្តិធ្វើការអមជាមួយផង ប្រទេសឥណ្ឌាក្នុងពេលនោះ បែងចែកជាច្រើនអាណាខេត្តដែលនៅក្នុងអធិស្សរភាព នៃឧបរាជឥណ្ឌា, ព្រមទាំង៦៩០រដ្ឋ ដែលនៅក្នុងការគ្រប់គ្រងព្រះមហាក្សត្រិយ៍សោយរាជ្យនៅឡើង ។

តាំងពីលោកមហាត្មៈគន្ធី បុព្វបុរសប្រទេសឥណ្ឌាបានតំណើរការនយោបាយតមក, តស៊ូដើម្បីឯករាជ្យប្រទេស ទើបនៅឆ្នាំ១៩៤៩ ប្រទេសឥណ្ឌាបានបែកជាពីររដ្ឋគឺ រដ្ឋហិណ្ឌូស្តង់ (សាធារណរដ្ឋហិណ្ឌូ) និងរដ្ឋប៉ាគីស្តង់ ។ អ្នកណាដែលហៅថាមហាត្មៈគន្ធី ?

លោកមហាត្មៈគន្ធីបដិសន្ធិនៅមាត់សមុទ្រអូម៉ង់ ក្រុងកាធីយ៉ាវ៉ារ រដ្ឋប៉ូរបង់ដារ ថ្ងៃទី២ តុលា គ.ស. ១៨៦៩ មរណភាពដោយណាធុរ៉ាំ វិនាយក គ័តសេ ពិឃាត នៅថ្ងៃសៅរ៍ ២៩ មករា គ.ស. ១៩៤៨ ។ លោកបានប្រើនយោបាយមួយហៅថា "អព្យាបាទ, ការមិនព្យាបាទអ្នកដទៃ" ។ លោកមហាត្មៈគន្ធី អង្គុយនៅក្នុងគេហដ្ឋានរបស់គាត់ ហើយគាត់រវៃកប្បាស ។ តាមមាត់ទ្វារផ្ទះមានរស្មីព្រះសុរិយាចាំងចូលទៅក្នុង, បំភ្លឺ-កំភួនជើងគាត់ទទេ, ស្គម, ក្បាលត្រងោល ។ នៅជុំវិញគាត់មានកល្យាណមិត្តនិង

សាវ័ករបស់គាត់ជាច្រើន, ខ្លះពួកមហាម័ត, ខ្លះពួកហិណ្ឌូ, ខ្លះពួកបណ្ឌាល ។ មានម្នាក់នាមអាប់ឌុល គាហ្វ៉ា:ខ័ន គាន់សាសនាមហាម័តជានាយកគណៈបក្សជាតិនិយម, លោកបណ្ឌិតវេជ្ជសាស្ត្រ អង់សារី, លោកម៉ូតិឡាល់ . នេហ៍រូ, ដែលគេសន្មតនាមថា «គជខ្សែក្រហម, លោករពិន្ទ្រណាថ-តាគុរ និងអ្នកស្រីស្លាដ . ជាស្ត្រីអង់គ្លេសដែលគេហៅថានាងមីរ៉ា-បេន ស្លៀកសារីពណ៌ស្វាយ ។

នៅទីនេះគេត្បៃស្បូវហ៊័តវៃ, ហើយលោកតាគុរពោលថា: "ពួកខាងបស្ចិមប្រទេសអួតថា" ផ្លូវរាំងឆ្ងាយតែងមានដើមមានចុង អញមុខជាទៅដល់ផ្លូវខាងចុងនោះមុនជាងគេជាប្រាកដ ។ ដោយយើងយល់ថាផ្លូវយើងគ្មានចុង, យើងក៏ស្ថិតនៅស្ងៀមខំគិតគូរពិចារណាតទៅទៀត " ។ លោកគន្ធីលើកក្រវាត់ក្រមាស ទៅលើស្មាគាត់ គេឃើញកែវនេត្រដែលមានគែមជុំវិញលាបលនដោយទឹកមាស ហើយគាត់បានបញ្ចេញនូវត្រចៀកគាត់វែងផុះពីសន្ធាងក្បាល ។

លោកញញឹមហើយក្នុងសេចក្តីញញឹមនោះចិត្តសង្ឃឹមនៃពួក ៣៥០ លាននាក់លើលោកថាមុខជាលោកនឹងកាច់បំបាក់នៅចក្រពត្តិនិយមអង់គ្លេស, នឹងរំលោភថ្វីដែលបក់បោកហ៊ុនរលាយបាត់នូវសភាពវណ្ណៈជាទស្សប់ទ្ទីម

លោកមហាត្មៈគន្ធីពោលថា: ត្រូវតែធ្វើ; ខ្ញុំបានអត់បាយដប់មួយដងហើយ ខ្ញុំបានគ្រាប់វគ្គាត់ មួយឆ្នាំមិនដឹងទិសតំបន់ ។ ហើយខ្ញុំនឹងវិលត្រឡប់ទៅគាន់ពួកបណ្ឌាលគឺពួកហរិជន គ្មានជនជាតិហិណ្ឌូណាម្នាក់ ទៅស្ងៀមមុននឹងបំពេញករណីយកិច្ចរបស់ខ្លួនចំពោះជនជាតិបណ្ឌាលទាំង ៥០លាននាក់ បងប្អូនទាំងអស់គ្នា . មិនមានថ្នាក់ខ្ពស់ណាស់ ឬទាបណាស់ ចំពោះមុខព្រះអាទិទេពៗត្រូវតែពួកព្រាហ្មណ៍, វៃស្យ,, សូទ្រៈ ហរិជន, ត្រូវតែពួកមហាម័ត, ពួកព្រាហ្មណ៍គ្រប់វណ្ណៈរួបរួមគ្នាដោយសាមគ្គីធម៌ដ៏រឹងប៉ឹងហើយទុកគ្នាជា បងប្អូនសាច់ឈាមជាមួយគ្នា....:

លោកអាប់ឌុលខ័នឆ្លើយឡើងថា " ដើម្បីតស៊ូនឹងប្រទេសអង់គ្លេស ។

លោកមហាត្មៈគន្ធីតបឡើងថា " ដើម្បីប្រទេសឥណ្ឌៀ ,, ។ (មានត)

## រឿងជូជក

### កាព្យពាក្យ ៧

មែនមានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក　រាងរូបអាក្រក់អន្ធការ　ស្គមប្រដាងខ្លួនកោងពើងស្មា
ត្រចៀកយូរយារដូចឃ្វង់ភ្លើង ។　ច្រមុះកោងច្រូងសឹងតែផ្អឹង　សក់ក្បាលកំប្រឹងបះកន្ទ្រើង
ពោះធំកំប៉ោងកែងកោងជើង　ភ្នែកស្រលៀងឡើងស្មើតស្រលើៗ　ក្បាលវែងតូចម្ខាងដូចផ្លែក្នោ
សាច់ពកយារទៅដូចគេផ្ញើ　ប៉ុនផ្លែក្រសាំងនឹងផ្លែល្មើ　គាត់ដើរសុំទានដោយបែបខ្លួន ។

បីថាពុំបានឯស្រុកគាត់ គ្រាប់ទៅឯវត្តអ្នកយើង(១)តូច ពុំបានឯជើងទៅឯត្បូង
អត់ឯទ្រទ្រូង(២)ទៅឯដេ ៗ អត់ពីលោកនេះទៅជូនជំ សុំតែគេសុំគ្មានចំនេរ
ត្រីងៀតត្រីឆ្អើរត្បាល់អង្រែ ផាមួងហូលក្រះមួសអំបិល ៗ ស៊ីកង្រែគ្រួរម្រេចខ្ទឹមរំដេង
គ្រប់ផ្ទះគ្រប់ល្វែងមួរអំពិល ប្រហុកផ្អកម៉ាំហើយគាត់រែល យកមកសំដិលទុកក្នុងផ្ទះ ៗ
គាត់សុំយ៉ាងនេះគិតបានជា មាសស្តោះសោភាចែងត្រចះ មួយរយដំឡឹងយ៉ាងពិតច្បាស់
ហើយគាត់ក៏យំណាស់ក្រែងចោរប្លន់ ៗ ទើបយកទៅផ្ញើនឹងព្រាហ្មណ៍ម្នាក់ ដែលជាក្មេងម្នាក់ស្និទ្ធក្រៃពេកពន់
លុះដល់ថ្ងៃក្រោយដ៏យូរលន់ ព្រាហ្មណ៍ប្ដីប្រពន្ធចាយរាយអស់ ៗ ជូជកខឹងណាស់គំហកថា
សាងសំពល់គ្នានឹងមានគ្រោះ ប្រាកដស្លាប់ខ្លួនមិនមែនរស់ ព្រោះអញស្គាល់អស់មុនទៅក្រុម ៗ
ព្រាហ្មណ៍ប្ដីប្រពន្ធខ្សឹបខ្សៀវគ្នា យើងកុំរញ្ញាកគិតបារម្ភ កូនក្រមុំយើងទើបនឹងធំ
ផ្សេផ្សំឲ្យគាត់កុំឲ្យក្ដៅ ៗ គិតស្រេចពុំលង់នាងព្រាហ្មណី ចូលទៅស្រដីយ៉ាងនេះវើ
តាអើយ ៗ តា! កុំមួម៉ៅ ខ្ញុំនឹងឲ្យទៅជាប្រពន្ធ ៗ ជូជកស្ដាប់ហើយឆ្លើយវិញថាន
ចុះនាងនោះប្រាណល្អល្ហាសល្ងន់ ប្ដីអាគ្រក់ទៅអប្បអន្ធ អញមិនឲ្យជួនខ្លួនឥតការណ៍ ៗ
ព្រាហ្មណីឆ្លើយថាល្អណាស់ខ្ញុំ ល្អអស់លើសស្រីក្នុងវត្ត ពាំខ្ញុំនាំមកឲ្យលោកតា
មើលតើស្នេហាប្ដីម្ដេចវិញ ៗ ឃើញហើយជូជកអរពេកក្រៃ ទឹកក្នុងជួងថៃឥតទោម្នេញ
រួសរៀបប្រដាប់ធាប់ចរចេញ ត្រឡប់វិលវិញឋានអាត្មា ៗ ជូជករួសរាយស្រស់ស្រាយពិត
នាំនាងអមិត្តាបនា អំពីឋាននោះតាមមាគ៌ា នាងអមិត្តាស្តាយយាមតាម ៗ
ឯតាជូជកដើរទៅហើយ ក្រឡេកងាកងើយញើសហោម ក្មេងគិតខ្សោយហត់ជើងចេញឈាម
ជួនគាត់ងាកក្ញាមឡកសំដី ៗ មិនយូរលង់ឡើយគាត់ស្រែកប្រាប់ អូនស្រស់ចំណាប់ដើរមុនប្ដី
ខ្លួនបងនឹងបានតន់ប្រិមប្រិយ ឲ្យអស់បេតីក្ដតណ្ហា អ៊ៃយ៉ា! នោះហ្ន៎អាកូនក្មេង
រ៉មកល្បួកលេងប្រពន្ធតា ព្រោះស្មានទារីថ្លៃកពីណា ទើបគាត់ស្រែកថាកុំរឺយកុំ ៗ
អញមិនខ្លាចទេថ្វីឯងក្មេង កុំមកលលេងអូនក្រមុំ អញហ៊ានជាល់តប់គ្មានជំទុំ
យកឯងទៅឃុំឲ្យស្គាល់តា ៗ ' ញុំហើយរាំធ្វើថាប្រាស់ព្រាត់! តាជូជកគាត់ចរយាត្រា

(១) ពាក្យគោរព សំរាប់ហៅបព្វជិតដោយចេញឈ្មោះ (លោកម្ចាស់-របស់យើង) (២) សមណៈស័ក្តិទីរាជាគណៈ

ស្តាយ យាមតាមនាងអមិត្តា
ខំដេរង់ងើលរកពង្រត់
ពិតមានកាសិតមួយកន្ទុង
អំពីអំពើវិនាសធាប់ ៗ
ស្រឡាញ់ពេញចិត្តប្រព្រឹត្តជាប់
ព្យាយាមអង្អែលទន្ទាប់ស្រស់
លុះត្រាចាប់ទៅដល់លំនៅហើយ
ចូរនាងតប់ប្រាណធ្វើសរសៃ ៗ
ជូជកស្រែកថាមេចស្រែង
ជូជកមឹតស្ទុងតាមរហ័ស
លុះឃើញអមិត្តាមកក្បែរ
ឈប់លែងគម្រាមហើយម្តងនេះ ៗ
អូនមើលក្បាលបងឈាមរឡេះ
ជព្រាហ្មណ៍លង់លុះដោយរតី
គាត់ខំស្វែងរកតាមដងព្រៃ
ព្រមទាំងបុត្រាពោធិសត្វ ៗ
ឲ្យធាប់ដល់ឋានពោធិសត្វ
ជូជកយាត្រាចរវិលវង
ចូលក្នុងបុរីស្រីសញ្ជ័យ
ជាដម្លៃគូរមួយចំហៀង ៗ
ក្នុងការស្នេហាឥតមានល្អៀង
បំណាគរគោករង្វង់ធាតុ
ខ្ទរស្រែកថាវឺយស្ងួតាំគ្មាន
ខ្ទះថាកុំទុកព្រួយឥតការណ៍ ៗ

បែកញើសគយារកាន់ឈើច្រត់ៗ
ស្រីកេន្ទបែបនេះយកមកមត់
ព្រះទ្រង់សំដែងរូបហើយតើ
“ចាស់ចើកបានជូនទូនក្រមុំ
របស់ក្តីផាប់ក់ទាំងអស់
ស៊ីមិនកើតក៏ហិតតែរស់
ជូជកកៀកកើយស្រស់កល្យាណ
អមិត្តាក៏តាំងដំរាយ
ចូរបន្ទយដៃអញឈឺណាស់ ៗ
ប៉ះឯងដួលដេងឡើងបះ
គាត់ធ្វើពូកែប្រឹងក្រោកក្ទាម
បែរជាអង្វរថាអូនស្រី
គតិថ្ងៃនេះបងថ្មស្រី ៗ
ទទួលបម្រើកែវប្រិមប្រិយ
ទ្រលឹងទ្រៃឈមូប់សាខា
គាន់ខំត្រាប់ទាំងយប់រាត្រី
ទឹងបានវិលថ្ងាត់ជួបព្រលឹង ៗ
ហេតុកម្មលាមកដំរួសរឹង
ព្រះអង្គទិញអេយ្យកានូវ
នគរឥតគិតស្តាយអ្វីសោះ
បំពោះចៅព្រៀងពីបុព្វជាតិ ៗ
ពោះបែកព្រោះលោភស៊ីជួជាតិ
មកអស់ពួកយើងរត់ត្រូក
អញបានឮគេប្រាប់យ៉ាងទៀង

ទុហ៎! នេះចំជាចាស់ព្រើល
ជាប្រពន្ធហត់ឥតអំពើ ៗ
ទឹងពួកទេវតាចុះពីលើ
ដោះក្បីពកប៉ុនផ្លែទន្ទាប់
រ៉ាំអ៊ុយកាលណាទឹងព្រមក្ចាម
ទាំងអស់ជាហេតុអន្តរធាន ៗ
ស្រដីថាអូនបងឈឺប្រាណ
ម៉ាំងៗស្ទើរខ្ទាយទុកក្ប្រៃ
អមិត្តាធ្វើបុករត់គ្គុង
ផ្ទាពោះតះៗក្បាលបេញឈាម ៗ
ហើយស្ទុះមកទុបឥតទឹមទាម
កុំធ្វើឲ្យប្តីព្រួយដូចេះ
ដំណាគតាំងពីថ្ងៃនោះ
វិល្វែងរកទាសីទឹងទាសា ៗ
ដើម្បីទឹងសូមពជជីតា
ពុំមានគិតក្តីព្រួយឈឺផ្កាត់
សុំបានបុត្រីទឹងបុត្រា
តាព្រាហ្មណ៍មិនដឹងរង្វើនផង ៗ
អយ្យកោទាំងពីរអង្គទ្រូវ
ដោយហេតុតែព្រោះសេចក្តីទៀង
ថ្ងៃនោះជូជកបានបរិភោគ
ឈូចរព្រោងព្រាតផ្អើលអ្នកស្រុកៗ
ចូលក្នុងព្រៃព្រឹក្សស្វែងក្តីសុខ
ថាព្រាហ្មណ៍ស៊ីលៀងក្លាយទុកក

គាត់ស៊ីផ្លែក្រៀលមួយត្រកបារ    ដុំទិនស្រាទុំបពាក ៗ    ប្រាប់ដំណើរប្រាំចរន្តត្រាន
បបរប្រាំថ្នាំងញាត់សម្រុក    ពោតស្នោរមួយស្ទឹកស្ពានស្រណុក    ស៊ីក្រេបក្តុំក្តុកអន្ទះសារ
រកខ្យល់ប្រទេស្លាតប្រកាច់ដួល    រម៉ុលរមួលស្រែកខ្ញួញថា    ឱកែវក្រមុំបងឈឺជ្រា
លែងឃើញពុំងាស្លាប់ទៅលោភៅ ៗ    ពោះដំព្រាហ្មណ៍ធំទ្រលុំ    ពុំមានពេទ្យគ្រូដាក់ថ្នាំត្រូវ
ស្ងួតកដាំតួងកណ្ដាលផ្លូវ    ធ្លាយពោះឈាមឆ្អៅហូរហាប ៗ    ជនានុជនទាំងស្រីប្រុស
កុំគិតផ្លូវខុសការខូចកាប    ត្រូវកុំឲ្យលុះដោយអំណាច    កាមាគុណ បដូចដួជក ៗ
មែនពិតរឿងកំភ្លែងលោកតា    ចាស់ខ្វះគាំទបុកអាក្រក់    ឃើញស្រីក្មេងៗតាំងឡកឡក់
ភ្លើងញាក់ញ៉ក់លលប្រឡាញ់ ៗ    ចាស់ខ្វះអាងលុយគាត់ទិញចាយ    ស្រីគេសហាយដោយប្រវ័ញ្ចន៍
ដូនម្ចាស់គេទាន់គេគ្នាន់គ្នាញ់    រាយតប់ប្រវ័ញ្ចវិនាសប្រាណ ៗ    ចាស់ខ្វះលបលួងល្បួងស្រីៗ
មិនទាន់ដឹងក្តីដោយក្លាហាន    រាប់ក្តីដាប់គុកវិនាសប្រាណ    រាយតប់គាក់ព្រានយេញញឹកញាប់
ខ្វះទៀតឃើញគេមេម៉ាយក្មេង    ចង់លួកលលេងស្មានក្តីគាប់    មិនដូចប្រាថ្នាប្រាថ្នាគាប់ ៗ
ចរចូលឡើងចាប់ក្នុងភក្រ្ត ៗ    គាខ្វះចាស់ស្ងូវប្រពន្ធមាន    មិនគិតស្មានទានសីលពុទ្ធ
ប្រពន្ធទៅបួសធ្វើជនជី    ឯងនៅកែវប្រពន្ធក្មេង ៗ    មិនតែប៉ុណ្ណោះគាត់ចង់រក
កែវស្រស់ពន្ធកត្រាន់លួកលេង    កែវខអផ្សុកផុកកំប្លែង    ទាស៊ីវិឯងក៏យកដែរ ៗ
ជូនថ្លៃមួយនោះនាងមេម៉ាយ    លែងប្តីសពោយរត់ទោលម៉ែ    មកស្នាក់ផ្ទះតាតក៏តាត់ថែ
នាងរត់មិនស្នេហ៍គាត់ប្តីទោទ ៗ    ថាលួចមាសប្រាក់សំពត់អាវ    ដើរស្រែកអំពាវឥតក្រែងកោត
ស្រីក្មេងមានក្មាសហេតុគ្នាទោត    ខ្វះការពិសោធន៍ចាញ់ជាប់គុក ៗ    តាអើយៗតា! សក់ស្កូវ
កុំស្ងូវប្រមូលយកក្តុំក្តុក    មកប្រលែងលេងស្មានក្តីសុខ    អួតអាងស្រណុកនោះតាអើយៗ

តែងដោយតាង–យកាំ សាន្ត បោកស៊ីង

សិស្សវិទ្យាល័យស៊ីសុវត្ថិ·

---

# រឿងមហាក្សត្រមួយព្រះអង្គ

ធិង សត្រ៉ុ ស៊ីញ៉ុល

យើងសូមនិទានជំរាបជូនលោកអ្នកអានទាំងឡាយ    អំពីរឿងល្បើកមួយដែលគេតែងដឹងស្គាល់

ជាច្រើនគ្នា ។ ពិតមែនតែរឿងល្បើកនេះគេបានប្រែចេញជាច្រើនភាសា រួចហើយ យ៉ាងណាក៏ដោយ ឯរឿងនៅតែដដែល ។ រឿងនេះអស់លោកអាន ទាំងឡាយក៏បានស្តាប់ដឹងៗ នឹងឃើញជាញឹកញយមកហើយ តែជារឿងដែលយើងចូលចិត្តជាទីបំផុត ។

ព្រះបានបង្កើតសកលលោក ហើយនឹងមនុស្សលោក ។ លោកបានបង្កើតនូវវត្ថុស័ក្តិសិទ្ធយ៉ាងសំខាន់ៗថែមទៀត ដើម្បីឲ្យមនុស្សអាចរកសុីសន្សំ ដូចជាភ្នំ មហាសាគរ ព្រៃព្រឹក្សា វាល ហើយនឹងរុក្ខជាតិ.ដើមឈើដែលឲ្យផលទាំងឡាយ ។ ល ។ លោកបានបង្កើតជា សត្វល្អិត ។ ហើយនឹងសត្វចតុបាទ ។ មានសត្វស្លាបជាច្រើន ដែលមានគិនភាគខុសពីគ្នា មានសត្វខ្លះចេះច្រៀងដូចជាសត្វរ៉ូស្សីញ៉ុលជាដើម

សត្វស្លាបនេះ គ្មានរូបរាងស្អាតបាតល្អទេ ប៉ុន្តែចេះច្រៀងពិរោះយ៉ាងចំណាន នៅលើផែនដីទាំងមូល ។ តមកនេះគឺរឿងសត្វរ៉ូស្សីញ៉ុល គឺជាសត្វស្លាបតែមួយដែលព្រះ បានបង្កើតទុកសំរាប់ជាកំសាន្តនៃកត្វព្រងសំណាង របស់មនុស្សលោក-មួយដែរ ។

កាលក្នុងសតវត្ស ជាយូរយារណាស់មកហើយ នោះនៃសម័យមួយ មានមហាក្សត្រមួយព្រះអង្គ មានអំណាចដ៏ក្រៃលែង សោយរាជសម្បត្តិលើប្រទេសនឹងមហាជនជាច្រើន ។ ព្រះអង្គទ្រង់គង់នៅក្នុងមហាប្រាសាទយ៉ាងល្អ វិសេសវិសាលមួយ ដែលមានបរិវារត្រៀបត្រានៅចាំបំរើ ។

ទុកជាព្រះអង្គមានបុណ្យអំណាចនឹងភោគសម្បត្តិជាច្រើនយ៉ាងអនេកអនន្តដូច្នេះក៏ដោយ គ្រប់ទៅជាមានព្រះរាជហឫទ័យ ត្រូវការនឹងចូលចិត្តស្តាប់ចំរៀងរបស់សត្វរ៉ូស្សីញ៉ុលទៅវិញ ។

នៅពេលនោះ ព្រះចៅមានអំណាចជាទីបំផុត ដែលគ្មាននរណាម្នាក់ហ៊ានបញ្ជាក់ នូវព្រះរាជឧង្ការផ្សេងៗថាដូច្នេះដូច្នោះមែនឬមិនមែនឡើយ ។ កិច្ចការអ្វីៗក៏ដោយ ត្រូវតែព្រះអង្គសំរេចសិនជាដំបូង ។ នៅពេលដែលព្រះអង្គទ្រង់យល់ច្បាស់ថា ព្រះអង្គមានអំណាចយ៉ាងមហាស្ចារ្យ ទ្រង់មានដំរិះថា

“ ហេតុអ្វីបានជាត្រូវចាំដល់ព្រលប់ទើបសត្វរ៉ូស្សីញ៉ុលចាប់ច្រៀង ? ដោយទ្រង់ក៏ខ្ញាល់ ទើបត្រាស់បង្គាប់ឲ្យពួកមហាជនដេញចាប់សត្វរ៉ូស្សីញ៉ុល យកទៅដាក់ក្នុងទ្រុង ហើយឲ្យយកមកទុកក្នុងព្រះក្រឡាបន្ទំជិតព្រះទែនរបស់ព្រះអង្គ ។ ដោយទ្រង់គិតថា ធ្វើដូច្នេះ ទើបអញបានស្តាប់ចម្រៀងសត្វរ៉ូស្សីញ៉ុលនេះនៅគ្រប់ពេលវេលា ។ ប៉ុន្តែការយល់របស់ព្រះមហាក្សត្រនេះ ខុសទៅវិញទទេ ។

(មានត)

# សូមកែពាក្យនិងអក្សរក្នុងលេខពិសេស

| ពាក្យថា | ទំព័រ | បន្ទាត់ | កែជា | ពាក្យថា | ទំព័រ | បន្ទាត់ | កែជា |
|---|---|---|---|---|---|---|---|
| លុពម្រិត | ១ | ៧ | សុពម្រិត្យ | ប្រទេស | ៣៣ | ២៥ | ប្រទេស |
| ពិតថា | " | ២៩ | ពិតជា | កៀន | ៣៥ | ១ | កៀន |
| ០០០៛ | ៧ | ១៩ | ៩០០០៛ | គេឯង | ៣៦ | ១៣ | ឯង |
| ៩១០០៛ | " | " | ១០០០៛ | មុនថា | ៣៧ | ១ | មុខជា |
| ាំងគ្រហស្ថ | ៨ | | ទាំងគ្រហស្ថ | ខ្ទួនអ្នក | ៣៦ | ១៩ | ខ្លួនអ្នក |
| បាសមណៈ | ៩ | ២៩ | បានសមណៈ | ប·យ! | ៣៧ | ៦ | ប-យ៉! |
| ប្រសើ | ១២ | ២ | ប្រសើរ | វាំជួបស្រាពាប់តែ | " | ១០:៧ | ពាំជួបស្រាប់តែ |
| ថ្ងំអំណារ | " | ៨ | ថ្ងៃអំណារ | កាន់កាប់ | ៣៩ | ៣៩ | កាន់កាប់ |
| អង់គ្លេស | ១៤ | ១ | អង់គ្លេស | ព្រះថេរៈ | ៤១ | ១៤ | ព្រះថេរៈ |
| យ៉ានទី | " | ១៦ | យ៉ានទុ | ទៅកាន់ | ៤២ | ១ | ទៅកាន់ |
| ថយថាន | " | ៣៤ | ថយជាន | គាត់ប្រមាន | " | ១៥ | គាត់មាន |
| ឈ្មុនិះ | ១៧ | ៣៤-៣៥ | ឈ្មោនស | ដម្បី | " | ១៧ | ដើម្បី |
| សបត្តិទុក | ១៨ | ២២ | សេបត្តិទុក | សត្វពាគញាញ | " | ១៩ | សត្វពាគញាណ |
| អនុគ្គិន | " | ៣៤ | អនុគ្គនស | មនមុន | " | ២៤ | មកមុន |
| ប្រសស្វីស | ២០ | ៣១ | ប្រទេសស្វ៊ីស | ព្រះនៃ | " | " | នៃព្រះ |
| ធ្វគាម | ២៤ | ៣៥ | ធ្វើគាម | ជម្ពីប | ៤៣ | ១ | ជម្ពូទ្វីប |
| អាក្យកិរិយា | ២៥ | ១ | អាកប្បកិរិយា | លដែល | " | ២-៣ | ដែល |
| (គូ៉) | ២២ | ៣២ | (គូរ៉) | រដ្ឋមន្ត្រី | " | ៦ | រដ្ឋមន្ត្រី |
| ដំពូក | ២៧ | ៣៦ | ដំពូក | ប្រជាជន់ | " | ១៨ | ប្រជាជន |
| បណ្ដាប់ | ២៩ | ៩ | បណ្ដាប់ | ដទៃទៀត | ៤៤ | ១៤ | ដទៃទៀត |
| ឧបត្ថម្ភ | ៣០ | ១០ | ឧបត្ថម្ភ | បស់ | ៤៥ | ១៤ | របស់ |
| ជួយខាង | ៣២ | ១៤ | ជួយខាង | ដម្ងៃ | ៤៥ | ១៥ | ដម្លៃ |

| | | | |
|---|---|---|---|
| ឆាប់សេកន់ | ,, | ៣៨ | ឆាប់ស្រេកន់ |
| សិទិ | ៤៦ | ៣ | សិទ្ធិ |
| យេង | ,, | ១៤ | យើង |
| មានសិទ្ធ | ,, | ១៨ | មានសិទ្ធិ |
| ក្នុងពល | ៤៧ | ៦ | ក្នុងពេល |
| សេចក្តីថ្លើយ | ៤៩ | ៣០ | សេចក្តីឆ្លើយ |
| ដូនគទៅ | , | ៣៥ | ដូចគេទៅ |
| ជាប្រលោម | ,, | ៣៦ | ជារឿងប្រលោម |
| និនព្ធ, រឿង | ,, | ៣៦ | និពន្ធរឿង; |
| រឿងហ្វឹង | ,, | ៤០ | រឿងហ៊ុង |
| អក្សរខ្មែ | ៥០ | ៣៨ | អក្សរខ្មែរ |
| គប់គោ | ៥៣ | ២៤ | គូប់គោ |
| ដាប់ខាត | ៥៤ | ២២ | ដាច់ខាត |
| ពកែ | ៥៥ | ២ | ពូកែ |
| ឲ! | ,, | ៩ | ឱ! |
| បេ | ,, | ៣០ | បើ |
| ហោយ | ,, | ៣៣ | ហើយ |
| គ្រប់លើ | ៥៧ | ២ | គ្របលើ |
| ធ្មើម្តេចហ្ន៎! | ,, | ២២ | ធ្វើម្តេចហ្ន៎! |
| ឲ្យវែង | ,, | ៤២ | ឲ្យវែង |
| មូលទៅ | ,, | ៤៤ | ចូលទៅ |
| ប់ណ្យ | ,, | ៤៦ | បុណ្យ |
| ក្រៀមក្រោះ | ៥៨ | ៤ | ក្រៀមក្រោះ |
| កមធ្វើ | ,, | ៦ | មកធ្វើ |
| គាមពត | ៦១ | ៣៥ | កាមពត |

| | | | |
|---|---|---|---|
| បេរលោក | ,, | ៤១ | បើរលោក |
| យើងកេត | ៤៦ | ១១ | ហើយកេត |
| ជនសា-រឿង | ,, | ១៧ | ជន - សារឿន |
| ពេញចិត្ត | ,, | ៣០ | ពេញចិត្ត |
| ដឹងរម្លគ្គា | ៦៣ | ៣៦ | ទឹងរម្លគ្គា |
| ទឹងភូមិភាគ | ៦៣ | ៣៩ | ទឹងភូមិភាគ |
| ក្នង | ,, | ៤៣ | ក្នង |
| អានាខែត្រ | | ៤៦ | អាណាខែត្រ |
| ទឹងឲ្យ | ៦៥ | ២ | ទឹងឲ្យ |
| ហត្ថលេ | ,, | ១០ | ហត្ថលេខា |
| ក្នអាស៊ី | ,, | ១៤ | ក្នុងអាស៊ី |
| ទង | ,, | ២៤ | ទឹង |
| ទទួលថា" | | ៣០ | ទទួល |
| ប្រទេសភាគី,, | | ៣២ | ប្រទេសភាគី |
| ប្រទេសខ្វួន | ៦៦ | ៨ | ប្រទេសខ្លួន |
| ពំពន់ | ,, | ១០ | ពុំទាន់ |
| សារប | ,, | ១០ | សារុប |
| ដែល | ,, | ១៤ | ដែល |
| សេដកិច្ច | ,, | ១៧ | សេដ្ឋកិច្ច |
| គ្រាប់ប្រទេស | ,, | ៤៣ | គ្រប់ប្រទេស |
| គោលការ | ៦៧ | ៩ | គោលការណ៍ |
| គ្រោះថ្នាក់ | ៥៨ | ៨ | គ្រោះថ្នាក់ |
| នៅដៃ | ,, | ៣៧ | នៅដៃ |
| ប្រពៃ | ៦០ | ៤ | ប្រពៃ |

មានតទៅទំព័រខាងដើម